យូរ៉េត អូន ! (ខ្ញុំសួរ) ម៉េចក៏អូនហាមបងពុំឲ្យស៊ើបសួររកការពិតអញ្ចឹង ?

ព្រោះអូនគិតថា ក្រែងលោមានគ្រោះថ្នាក់ដល់បង ព្រោះគេជាអ្នកមានអំណាច មានឥទ្ធិពល ...

— ទេ ! បងដូចជាពុំឃើញថា មានគ្រោះថ្នាក់អីទេ — ថ្វីបើគេមានអំណាច គេអាចសម្លាប់រូបបងលេងៗបាន ឬ ? ស្រុកនេះ ជាស្រុកមានច្បាប់ទម្លាប់ យើងពុំគួរជាខ្លាចអញ្ចឹងសោះ ។

ណ្ហើយ ខាតពេលឥតប្រយោជន៍ទេ — រឿងរបស់គេស្រេចនឹងគេទៅចុះ — សុំបងបណ្ដោយទុកឲ្យវាងងឹតងងល់អញ្ចឹងទៅចុះ — បងមើលមើល៍ ផ្ទៃមេឃទាំងមូលជាផ្ទៃមេឃងងឹត — ងងឹតដូចជារឿងរ៉ាវក្នុងជីវិតនៃមនុស្សដែរ ..

ពិតដូចពាក្យដែលនាង យូរ៉េត និយាយមែន ។ ពេលនោះយើងឋិតនៅក្នុងសភាពងងឹត ។ នាង យូរ៉េត ប្រុង



ប្រៀបរៀបចំតុផ្កាភ្លើងនៅពេលដែលខ្ញុំទៅដល់ តែខ្ញុំបានហាមកុំឲ្យអុជ ព្រោះពុំមែនជាការចាំបាច់ ។ ខ្ញុំគិតថា គ្រាខ្លះ ឱកាសខ្លះ និងក្នុងសភាវការណ៍ខ្លះ សភាពងងឹតបានផ្ដល់នូវការរីករាយដល់យើង ជាជាងសភាពភ្លឺ ។

ផ្ទះរបស់មីងនេះ មានយ៉ខាងមុខបន្តិច ។ យ៉ានេះ ជាវិមានសួគ៌របស់យើង ។ ដើមម៉ាលើយ៉នៃផ្ទះនោះ បានផ្ដល់នូវសេចក្ដីសុខឲ្យយើង ពិបាកនឹងបំភ្លេចពេលបានក្នុងជីវិតនេះ ព្រោះមាននាង យូរ៉េត នៅជិតខ្ញុំ ។

ខ្ញុំធ្លាក់ខ្លួនចុះក្នុងអន្លង់ស្នេហ៍របស់នាងយ៉ាងពិតប្រាកដ តែខ្ញុំយល់ថា ការនេះ ពុំមែនមកពីសភាពនៃទឹកចិត្តមិនរឹងប៉ឹងរបស់ខ្ញុំ ឬក៏នាង យូរ៉េត មានស្នេហ៍ ឬមានអំណាចអាចស្រូបទាញទឹកចិត្តបុរសឲ្យវង្វេងនោះឡើយ ។ យើងទាំងគ្នាអង្គុយសំឡឹងមើលមេឃ ។ យើងរឹតតែឃើញច្បាស់តាមពាក្យដែលគេតែងនិយាយថា ផ្ទៃមេឃរឹតតែងងឹត ផ្កាយរឹត

តែភ្លឺទៀនមែន ។ កាលបើឃើញសភាពដូច្នេះ ខ្ញុំក៏គិតថា យើងនឹងដឹងដល់មិត្តល្អ ឬ មិត្តអាក្រក់នោះ ក្នុងខណៈដែល យើងធ្លាក់ខ្លួនទៅក្នុងសេចក្ដីទុក្ខលំបាក ដែលទុកដូចជាសភាព ងងឹតនេះ ។ ក្នុងសម័យរុងរឿងដែលទុកដូចជាពេលភ្លឺ យើង ក៏ពិបាកដឹងថា មិត្តណាល្អ មិត្តណាអាក្រក់ ។

យើងនាំគ្នាអង្គុយសំឡឹងហ្វូងតារាលើផ្ទៃមេឃ ហើយ យើងសួរគ្នាលេងថា ផ្កាយណាជាផ្កាយប្រចាំជីវិតរបស់អ្នក ណា ? នាងយូរ៉េត ចូលចិត្តតែរើសយកផ្កាយណាដែល ធំៗ ហើយក៏ថាជាផ្កាយប្រចាំជីវិតរបស់ខ្ញុំ ហើយនាង រើសយកផ្កាយណាដែលតូចៗ មានពន្លឺស្រអាប់ៗ ថាជា ផ្កាយប្រចាំជីវិតរបស់នាង តែផ្កាយដែលនាងរើសយកថាជា ផ្កាយប្រចាំជីវិតរបស់នាងនោះ នាងក៏រើសយកតែផ្កាយតូចៗ ណាដែលឋិតនៅជិតផ្កាយធំៗ ដែលនាងប្រាប់ថា ជាផ្កាយ ប្រចាំជីវិតរបស់ខ្ញុំ ។ យើងភ្ជាប់ធ្វើសច្ចាប្រណិធានចំពោះ



មុខដួងតារាទាំងនោះ ដោយសុំឲ្យដួងតារាទាំងនោះ ជួយធ្វើ ជាសាក្សីទិព្វរបស់យើងថា យើងនឹងស្មោះត្រង់រកគ្នា ដោយ មិនបោះបង់គ្នាពេលអស់មួយជីវិត ។

ខ្ញុំហ៊ានស្បថចំពោះវត្ថុស័ក្ដិសិទ្ធិថា ខ្ញុំពុំដែលប្រព្រឹត្ត លើសលើសលស់លើរូបនាងយូរ៉េត ក្រៅពីការថ្នបថ្នម ឡើយ ។ ខ្ញុំលើកនាងទុកដូចជាទេពអប្សរនៃការស្អាតល្អ បរិសុទ្ធ ។ ខ្ញុំនឹងខំព្យាយាមរក្សាទុកនូវគុណសម្បត្តិទាំងនោះ ឲ្យបាននៅយូរជាទីបំផុត ដែលខ្ញុំអាចរក្សាទុកបាន ។ នាង យូរ៉េតបានទុកចិត្តខ្ញុំ ។ ប្រសិនបើខ្ញុំប្រព្រឹត្តលើសលស់ លើនាងជាងនោះទៅទៀត ខ្ញុំជឿជាក់ថា នាងមុខជាបណ្ដោយ តាមចិត្តខ្ញុំទាំងអស់ តែខ្ញុំស្រឡាញ់នាង ស្រឡាញ់ដោយទឹក ចិត្តដ៏បរិសុទ្ធ ។ សេចក្ដីស្នេហាដ៏បរិសុទ្ធនេះ បានហាមប្រាម នូវគំនិតអាក្រក់របស់ខ្ញុំ ខ្ញុំចង់ឃើញនាងយូរ៉េត ឋិតនៅ បរិសុទ្ធស្អាត ដូចបុប្ផាដែលរីកឡើងជាប់នៅនឹងសណ្ដាន់ ឲ្យ

បានយើនយូជាទីបំផុត ដែលអាចបិតនៅបាន ។ ខ្ញុំអាចសរសើរខ្លួនឯងបានថា ខ្ញុំអាចរក្សានូវការបរិសុទ្ធរបស់ស្ត្រីគេទុកបាន សូម្បីនៅជាមួយគ្នាតែពីរនាក់អស់ពេលដ៏យូរក៏ដោយ ។

យប់មួយ នាង យូរ៉េត បានថ្លែងនូវការព្រួយបារម្ភប្រាប់ខ្ញុំថា នាងបានសង្កេតឃើញបុរសចំឡែកពីរនាក់ចេះតែនាំគ្នាដើរចុះឡើងកាត់មុខផ្ទះនេះ ហើយចេះតែងាកមើលមកក្នុងផ្ទះដោយការសង្កេតពិនិត្យ ។ នាងគិតថា ក្រែងបុរសចំឡែកទាំងពីរនាក់នោះ ជាដៃដើងរបស់លោកអនុសេនីយទោ ស៊ី ។

ការនេះ បានធ្វើឲ្យខ្ញុំព្រួយបារម្ភដែរ ព្រោះក្រែងមានរឿងមិនល្អកើតឡើង ។ នាង យូរ៉េត បានបញ្ចេញយោបល់ថា ប្រសិនបើរឿងនេះ បានលេចឮដល់អនុសេនីយទោ ស៊ី ពិតមែន គួរតែផ្លាស់ទីកន្លែងយ៉ាងឆាប់ជាទីបំផុត ដើម្បីកុំឲ្យមានការអ្វីកើតឡើងបាន ។



ការធ្ងន់ធ្ងរក្នុងចិត្តបានកើតឡើងដល់ខ្ញុំហើយ ព្រោះម្យ៉ាងក្រែងលោកសក្តិពីរ ស៊ី ដឹងថាខ្ញុំនាំនាង យូរ៉េត យកមកលាក់ទុកនៅកន្លែងនេះ ហើយម្យ៉ាងទៀត រឿងឪពុកម្តាយរបស់ខ្ញុំ ដែលចេះតែបង្ខំខ្ញុំឲ្យរៀបការជាមួយនឹងនារីម្នាក់ដែលខ្ញុំពុំពេញចិត្ត ។ រឿងនេះខ្ញុំបានសារភាពអង្វរករលោកពីរបីដងហើយថា ខ្ញុំពុំអាចរៀបការបានឡើយ ព្រោះខ្ញុំបានជាស្រឡាញ់នាង យូរ៉េត ជ្រុលទៅហើយ ប៉ុន្តែលោកពុំព្រមតាល់តែសោះ ។ រហូតដល់ទីបំផុត លោកបាននិយាយយ៉ាងដាច់អហង្ការថា លោកនឹងពុំព្រមឲ្យខ្ញុំយកនាង យូរ៉េត ធ្វើជាប្រពន្ធជាដាច់ខាត ។ ប្រសិនបើខ្ញុំពុំប្រតិបត្តិតាមលោកទេនោះ លោកនឹងកាត់កាល់ខ្ញុំចោល ។

ខ្ញុំចង់ប្រាប់នាង យូរ៉េត ពីរឿងនេះពីរបីដងមកហើយ តែខ្ញុំពុំហ៊ានប្រាប់ ព្រោះគិតថា ប្រសិនបើខ្ញុំប្រាប់នាងទៅ នាងមុខជាខូចចិត្តខូចថ្លើមជាពុំខាន ។

ខ្ញុំដកដង្ហើមធំ ព្រោះការពិបាកចិត្ត ។ ក្នុងខណៈនេះ ខ្ញុំហាក់ដូចជាមានកម្មកសង្កត់នៅលើដើមទ្រូងពីរត្រួត ។ មួយត្រួតគឺនារីជាទីស្នេហា មួយត្រួតទៀតគឺសត្រូវ ហើយ មួយត្រួតទៀតគឺឪពុកម្ដាយ

សំកប់រឿងអ្វីផ្សេង ពុំជាការអ្វីឡើយ ។ ប៉ុន្តែរឿងឪពុកម្ដាយនិងនារីជាទីស្នេហានោះ ជាបញ្ហាដែលខ្ញុំពិបាកនឹងដោះស្រាយបាន ព្រោះតាំងពីដើមរៀងមក ខ្ញុំបានតាំងខ្លួនជាកូនដ៏ល្អ ជាកូនដែលឋិតនៅក្នុងឱវាទរបស់ឪពុកម្ដាយជានិច្ច ។ ក្នុងវ័យសិក្សារៀនសូត្រ ខ្ញុំតែងប្រព្រឹត្តខ្លួនបានល្អជាប ។ រឿងស្នេហាពុំដែលមានក្នុងជីវភាពសិក្សារបស់ខ្ញុំឡើយ ។ មើលទៅប្រហែលជាដោយសារហេតុយ៉ាងនោះក៏ពុំដឹង បានជាឪពុកម្ដាយរបស់ខ្ញុំបានសម្រេចចិត្តរើសរកប្រពន្ធឲ្យខ្ញុំដោយមិនបាច់សាកសួរដល់ការពេញចិត្តរបស់ខ្ញុំផងនោះ ។

ខ្ញុំនឹងធ្វើដូចម្ដេច កាលបើខ្ញុំបានជាស្រឡាញ់នាង



យូរ៉េត ជ្រុលហួសទៅហើយ ។ សេចក្ដីស្រឡាញ់នោះ ក៏បានកើតខ្លួនឡើងធំណាស់ទៅហើយ? បញ្ហានេះ ធំជាងបញ្ហាអ្វីផ្សេងទាំងអស់ ដែលខ្ញុំធ្លាប់បានជួបប្រទះមកក្នុងជីវិត ។ ខ្ញុំអាចលះបង់អ្វីផ្សេងបានទាំងអស់ ដើម្បីនាង យូរ៉េត តែខ្ញុំពុំអាចលះបង់អ្នកមានគុណពោល ដើម្បីនាង យូរ៉េត បានឡើយ ។

ប៉ុន្តែថ្វីបើមានការពិបាកចិត្តច្រើនថែបយ៉ាងនេះក៏ដោយ ខ្ញុំគិតថា ពេលនេះ គួរតែដោះស្រាយរឿងផ្ទាល់ចិត្តខ្លួនជាមុនសិន ដោយទុកបញ្ហាផ្សេងដោះស្រាយជាក្រោយ ។ ខ្ញុំបានសម្រេចចិត្តថា នឹងនាំនាង យូរ៉េត ឲ្យទៅនៅជាមួយនឹងមីងថែម ឯភូមិពោធិហ្គស្រី ឃុំចំការសំរោង (បាត់ដំបង) ព្រោះខ្ញុំគិតថា ទីនោះឆ្ងាយពីក្រុងពុំងាយនឹងអ្នកណាតាមរកឃើញ ។

— ការនេះ មិនធ្វើឲ្យបងពិបាកណាស់ទៅហើយ ?

(នាង យូរ៉េត សួរខ្ញុំ) ព្រោះបងជាប់ធ្វើការផង ។

- មិនអីទេ ចាំបងចាត់ការរកស្ត្រីម្នាក់ ដែលបងទុកចិត្ត ឲ្យជូនអូនទៅ ។

- ប្រែសេចក្ដីថា យើងពុំងាយបានជួបគ្នាទៀតទេ ។

- ពុំមែនអញ្ចឹងទេ បងពឹងឲ្យគេជូនអូនទៅមុន ហើយ បើយូរណាស់ដប់ថ្ងៃទៀត បងនឹងលៃលករកពេលទៅតាម អូនហើយ ។

- អញ្ចឹងបងក៏នៅតែពិបាកដែរ ព្រោះខាតពេលទៅ តាមអូន ។

- មិនជាការអីទេសំរាប់រូបបង ព្រោះដូចបងធ្លាប់បាន និយាយប្រាប់អូនហើយថា បងអាចលះបង់ពេលវេលា ដើម្បី យូរ៉េត បាន ។

យើងបានកំណត់ពេលថា ត្រូវរៀបចំចាត់ចែងឲ្យ យូរ៉េត ធ្វើដំណើរទៅស្រុកពោធិញ្ញស្រ៊ី (បាត់ដំបង) នៅ ព្រឹកស្អែក តាមអយស្ម័យរថ ជាមួយនឹងនាងសាមុន ជាកូន



មីងដែម ដែលខ្ញុំបានពឹងពាក់ឲ្យជូនទៅ ។ ខ្ញុំបានលានាង ត្រឡប់ទៅផ្ទះវិញ ដើម្បីចាត់ការក្នុងរឿងនេះ ។

ខណៈនោះ នាងយូរ៉េតឱបខ្ញុំ ។ នេះជាគ្រាដំបូង ដែលនាងឱបហើយថើបខ្ញុំ ព្រមទាំងខ្សឹបដាក់ត្រចៀកខ្ញុំថា ៖

- អូននឹងមិនភ្លេចគុណបងអស់មួយជីវិត ។

ខ្ញុំពុំដឹងជាឆ្លើយថាដូចម្ដេច ។ យើងនាំគ្នាឈរនៅ ស្ងៀមមួយសន្ទុះ បណ្ដោយពេលវេលាឲ្យកន្លងផុតទៅ ក្នុង ការឱបថើប ដោយមិនបាច់និយាយស្ដីអ្វីឡើយ ។

- បង ! (នាងយូរ៉េតនិយាយថែមទៀត) សុំបង កុំបោះបង់ចោល យូរ៉េត ណ៎ាបងណ៎ា ! . . .

ខ្ញុំបានទទួលនូវពាក្យសន្យា ហើយខ្ញុំក៏ដើរមក ដោយ អនោសរមោតនាដែលពិបាកនឹងអធិប្បាយ ។ ខ្ញុំចុះចេញពីផ្ទះ នោះមកទាំងការពិបាកចិត្តនិងសប្បាយចិត្ត ។ ការដែលធ្វើ ឲ្យខ្ញុំពិបាកចិត្តនោះ គឺការដែលខ្ញុំនឹកទៅដល់រឿងដែលឪពុក

ម្ដាយខ្ញុំបានបង្ខំខ្ញុំ ឲ្យរៀបការប្រពន្ធ ឯការដែលធ្វើឲ្យខ្ញុំសប្បាយចិត្តនោះ គឺការដែលខ្ញុំទឹកពេញចិត្តក្នុងការសម្រេចរបស់ខ្ញុំ ... ខ្ញុំទឹកសប្បាយរីករាយតែក្នុងចិត្តថា រឿងល្ខោនជីវិតរបស់ខ្ញុំហៀបនឹងបានសម្រេចទីអវសានហើយ ។

នៅវេលាម៉ោង ៨ កន្លះព្រឹក ខ្ញុំក៏បាននាំនាងសាមុនទៅទទួលនាង យូរ៉េត ឯស្ទឹងមានជ័យយកទៅដាក់នៅស្ថានីយអយស្ម័យយានដោយរថយន្ត ។ ខ្ញុំបាននិយាយណែនាំអ្នកទាំងពីរឲ្យស្គាល់គ្នា ហើយបានបញ្ជាក់ប្រាប់នាង យូរ៉េត ថា នាងសាមុននេះឯងហើយ ដែលត្រូវជូនទៅនៅឯផ្ទះនាងនៅភូមិពោធិហ្មស្រី ។

យើងបានបែកគ្នាទាំងក្រៀមក្រំទាំងក្ដីអាល័យ ។

×
× ×

វគ្គទី ៦

# លាហើយស្នេហា

មួយសប្ដាហ៍ក្រោយមក ខ្ញុំក៏បានធ្វើដំណើរទៅតាមនាង យូរ៉េត ឯស្រុកពោធិហ្មស្រី ជាមួយនឹង សុខ-សម្បូរ ជាមិត្តចិត្តមួយរបស់ខ្ញុំ ។

នៅពោធិហ្មស្រី គ្មានហេតុការណ៍អ្វីនឹងពោលក្រៅពីការសប្បាយរីករាយ ដែលខ្ញុំបានជួបនាង យូរ៉េត ឡើយ ។

ទេសភាពនៃវាលស្រែដ៏ធំល្វឹងល្វើយ បានធ្វើឲ្យខ្ញុំចាំពុំភ្លេច ... យើងតែងនាំគ្នាដើរលេងនៅពេលល្ងាច ដើម្បីស្រូបយកអាកាសត្រជាក់ដ៏ល្អបរិសុទ្ធនៅវាលស្រែ ...

នៅថ្ងៃទី ៣ ថ្ងៃដែលខ្ញុំគិតថា ជាថ្ងៃត្រេកសំកប់របស់ខ្ញុំ ខ្ញុំទឹកដល់រឿងឪពុកម្ដាយរបស់ខ្ញុំ ដែលបង្ខំខ្ញុំឲ្យរៀបមង្គលការ ... ទឹកដល់រឿងនេះកាលណា ខ្ញុំព្រួយចិត្តពេលនោះ ព្រោះខ្ញុំដោះស្រាយបញ្ហានោះពុំរួច ... ខ្ញុំបាននិយាយរឿង

នេះប្រាប់ សុខ សម្បូរ ដោយល្អិតល្អន់... ទីបំផុត គេក៏បានសួរមកខ្ញុំវិញថា :

— បើអញ្ចឹងឯងគិតយ៉ាងម៉េច ?

— ទេ ! គ្នាពុំដឹងគិតយ៉ាងម៉េចទេ ! គ្នាសុំឲ្យឯងជួយគិតផងទៅចុះ ។

— ឯងនឹងឲ្យគ្នាធ្វើយ៉ាងម៉េចបាន ព្រោះរឿងនេះពុំមែនជារឿងរបស់គ្នា ។

— ចុះបើឧបមាថា រឿងនេះជារឿងរបស់ឯងវិញ ? ឯងនឹងសម្រេចយ៉ាងណា ?

— ចុះខាងណាល្អជាង !

— ចាញ់ យូរ៉េក ឆ្ងាយណាស់ ។

— ចុះនិស្ស័យចិត្តថ្លើម ខាងណាស្រួលជាង ?

— រឿងនេះគ្នាពុំដឹងទេ ព្រោះគ្នាពុំដែលបានស្គាល់គិតនិតជិតស្និតស្នាលនឹងខាងខាងណោះ — តែសំរាប់ខាង យូរ៉េក



វិញនោះ គ្នាពេញចិត្តគ្រប់យ៉ាង — គ្នាពុំជឿថានឹងរកគូជីវិតឯណាឲ្យវិសេសវិសាលជាង យូរ៉េក បានឡើយ ។

— នេះ ជាបញ្ហានៃការជ្រើសរើស ស្រេចហើយតែឯងជ្រើសរើសយកខាងណាដែលឯងយល់ថាគួរទៅចុះ ។

— បើជ្រើសរើសស្ត្រី ឬ ជ្រើសរើសប្រពន្ធនោះ ក៏បេះតែបានទេ តែបើជ្រើសរើសឪពុកម្ដាយ និង ប្រពន្ធនោះ មិនងាយឡើយ មិនថាអញ្ចឹង ?

— ចុះបើឯងដាក់បលោកតាមត្រង់ ហើយសុំអង្វរករលោកទៅមិនបានឬ ?

— គ្នាបានប្រើវិធីនេះរួចហើយ តែលោកពុំព្រមដាច់ខាត ។

— បើឯងដាក់បលោកតាមត្រង់ ហើយបណ្ដោយឲ្យលោកខឹងបន្តិចទៅ ក៏អស់រឿងទៅហើយ ។

— សំរាប់អ្នកដទៃឃើញថាធ្វើបាន តែសំរាប់ឪពុក

ម្ដាយគ្នា មើលទៅដូចជាធ្វើពុំបានទេ ហើយចំពោះឪពុកគ្នា មើលទៅពុំសូវជាអីទេ លោកគង់យល់ចិត្តថ្មើមគ្នាខ្លះៗដែរ តែចំពោះម្ដាយរបស់គ្នាវិញ ពុំបានជាជាប់ខាត ។

— ចុះបើអញ្ចឹង តើឯងគិតធ្វើយ៉ាងម៉េច ?

— ពុំដឹងទេ ។

— ចុះបើអញ្ចឹង គួរប្រាប់រឿងនេះឲ្យនាង យូរ៉ែត បានដឹងផងដែរ ឬទេ ?

— ក៏គួរតែប្រាប់ឲ្យគ្នាដឹងដែរ ?

— ចុះគួរនឹងប្រាប់ដោយវិធីណា ?

— ហ្នឹងគ្នាក៏ពុំដឹងទៀត ។

— ប្រែសេចក្ដីថា ឯងពុំដឹងស្អីទាំងអស់តែម្ដង ឬទេ ?

— ព្រោះបញ្ហានេះធំហើយពិបាកដោះស្រាយជាងបញ្ហាអីទាំងអស់ — គ្នាអាចលះបង់ស្អីគ្រប់យ៉ាង ដើម្បី យូរ៉ែត បានទាំងអស់ តែគ្នាពុំអាចលះបង់ឪពុកម្ដាយចោល ដើម្បី យូរ៉ែត ឡើយ ។



— បើអញ្ចឹង ឯងជាប់ចិត្តតាមឪពុកម្ដាយឯង ?

— ត្រង់ហ្នឹងក៏គ្នាពុំដឹងដែរ ។

— ចុះបើឯងពុំដឹងអីទាំងអស់អញ្ចឹង ឲ្យគ្នាធ្វើម៉េច ?

— ឯងជួយគ្នាបន្តិចបាន ឬទេ ?

— ឯងចង់ឲ្យគ្នាធ្វើអី គ្នានឹងធ្វើទាំងអស់ ។

— គ្នាសុំពឹងឯងឲ្យនិយាយរឿងនេះប្រាប់ដល់នាង យូរ៉ែត ។

— ចុះម៉េចក៏ឯងពុំប្រាប់ខ្លួនឯង ?

— គ្នាដូចជាគេហាមាត់ពុំរួច ។

— គ្នាពុំដែលនឹកថា ឯងខ្លាចដល់ម្ល៉ឹងណោះ ។

— គ្នាពុំដែលខ្លាចអីអញ្ចឹងមែន តែពេលនេះ គ្នាបានក្លាយខ្លួនទៅជាមនុស្សកំឡាចកំសាកញីទៅហើយ ។

សុខ-សម្បូរ បានទទួលនាទី ជាអ្នកនាំរឿងនេះទៅប្រាប់នាង យូរ៉ែត ។ ខ្ញុំសង្កេតឃើញថា គេត្រូវប្រើ

ពេលវេលាគិតច្រើនណាស់ដែរថានឹងទៅប្រាប់នាងដូចម្ដេច ? ប្រហែលជានឹងមួយម៉ោង បានគេដាច់ចិត្តទៅប្រាប់ ។

គេបានត្រឡប់មកប្រាប់ខ្ញុំវិញថា នាង យូរ៉ែត បានដេញដោលសាកសួរគេជាច្រើន ។ ទីបំផុត នាងកាត់ចិត្តថា ខ្ញុំត្រូវតែចូលខ្លួនទៅរៀបមង្គលការតាមបំណងរបស់ឪពុកម្ដាយ តែនាងត្រូវការជួបនឹងខ្ញុំ ដើម្បីពិភាក្សាគ្នាក្នុងរឿងនេះ នៅពេលឥឡូវនេះឯង ។

ខ្ញុំទទួលខ្លួនថា ក្នុងការចូលទៅជួបនឹងនាង យូរ៉ែត ក្នុងគ្រានេះ ខ្ញុំខ្លាចជាងការចូលទៅក្រាបបង្គំគាល់ម្ចាស់ផែនដី ឬខ្លាចជាងការចូលទៅជួបមុខសត្រូវ ដែលត្រូវតែស៊ូប្ដូរជីវិតគ្នាទៅទៀត ។ ខ្ញុំញាក់ថ្ងើមក្ដុក ក្នុងខណៈឃើញនាង យូរ៉ែត ។ ខ្ញុំគេនិយាយស្ដីអ្វីពុំរួច ។

— បង ! លោក សម្បូរ បាននិយាយប្រាប់ខ្ញុំពីរឿងបងអស់ហើយ — បងនឹងត្រូវតែបំពេញតាមបំណងលោកអ្នកមានគុណទៅមិនជាអញ្ចឹង ?



ខ្ញុំពុំឆ្លើយថាអ្វី ព្រោះដូចជាណែនបំពង់ករកនិយាយស្ដីជាអ្វីពុំរួច ។

— សុំកប់រូបអូន (នាងយូរ៉ែតនិយាយឡើងទៀត) អូនបានប្ដេជ្ញាចិត្តរួចស្រេចហើយថា អូនស្រឡាញ់តែរូបបងម្នាក់ក្នុងជីវិត — អូនប្រគល់ជីវិតជូនបង — តែបើដូច្នេះ សុំបងបំពេញតាមបំណងរបស់លោកឪពុកអ្នកម្ដាយទៅចុះ — អូនបានប្ដេជ្ញាទៀតថា អូននឹងពុំបូជាជីវិតស្នេហានេះ ឲ្យប្រុសដទៃក្រៅពីរូបបងឡើយ ថ្វីបើយើងពុំបានចួបនៅរួមរ័កជាមួយគ្នាក៏ដោយ...

ខ្ញុំពុំអាចនិយាយឆ្លើយឆ្លងនឹងពាក្យសំដីរបស់នាង យូរ៉ែត បានឡើយ ។

— ការនេះ ពុំមែនជាកំហុសរបស់ឪពុកម្ដាយទេ (នាង យូរ៉ែត និយាយ) ព្រោះឪពុកម្ដាយគ្រប់រូបសុទ្ធតែចង់សាងអនាគតដ៏ល្អប្រសើរ ឲ្យកូនទៅតាមផ្លូវដែលលោកយល់ឃើញថាល្អ — យើងត្រូវតែស្ដាប់ ។

– ចុះ យូរទេ ? (ខ្ញុំសួរ)

– អូនចេះតែនៅទ្រាំតាមគម្រូរបស់អូនអញ្ចឹងទៅ អូនឥតត្រូវការរៀបការជាមួយអ្នកណាជាដាច់ខាត អូនប្ដូរជាចំពោះតែបងម្នាក់ប៉ុណ្ណោះ ... បងក៏ត្រូវទុកចិត្តចំពោះអូនក្នុងរឿងនេះបានដែរថា អូននឹងពុំប្រគល់ខ្លួនឲ្យប្រុសណាដទៃទៀតក្រៅពីរូបបងឡើយ ។

សំដីនេះ ជាសំដីដែលមានគុណភាពអាចចូលទៅកាត់ទងបេះដូងរបស់ខ្ញុំ ... ខ្ញុំពុំដឹងជានឹងនិយាយជាមួយដូចម្ដេចតទៅទៀត ...

-- ចុះបងកំណត់ពេល ត្រឡប់ទៅភ្នំពេញវិញនៅថ្ងៃណា ?

-- ត្រូវទៅស្អែក ព្រោះសុំច្បាប់បានតែប្រាំថ្ងៃ ។

-- អូនត្រូវជូនបងទៅដល់ចាត់ជិះបង ។

សភាពរបស់ខ្ញុំក្នុងវេលានេះ ដូចក្មេងដែលគោតប្លន់



ទៅ គ្មានដឹងការអ្វី ក្រៅពីការចាំស្ដាប់ និងប្រតិបត្តិតាមពាក្យសំដីរបស់ឪពុកម្ដាយ ពាក្យសំដីរបស់មិត្តភក្តិ ពាក្យសំដីរបស់នារីជាទីស្នេហា ហើយលុះត្រឡប់ទៅដល់ភ្នំពេញវិញ ក៏ប្រុងប្រៀបខ្លួនចូលទៅកាន់ពិធីមង្គលការ តាមបំណងដ៏ធំរបស់ឪពុកម្ដាយ ហើយក្រោយពិធីមង្គលការនោះទៅ ខ្ញុំក៏នឹងត្រូវទៅនៅជាមួយនារីម្នាក់ដែលខ្ញុំពុំដែលស្រឡាញ់ ព្រមទាំងត្រូវប្រតិបត្តិតាមពាក្យសំដីរបស់គេទៀត ព្រោះគេនឹងត្រូវជាប្រពន្ធ ។ ក្នុងវេលានេះ ខ្ញុំលែងគិតអ្វីឃើញទាំងអស់ ក្រៅពីការដែលត្រូវនាំខ្លួនចូលទៅក្នុងទ្រុងដែក ក្នុងអនាគតដ៏ឆាប់របស់នារីដែលឪពុកម្ដាយរកឲ្យ ដោយខ្ញុំត្រូវតែជឿតាមថា ជាមនុស្សល្អត្រឹមត្រូវ ព្រោះឪពុកម្ដាយនឹងពុំសាងអនាគតដ៏ខ្មៅងងឹតឲ្យកូនឡើយ ។

មុនពេលធ្វើដំណើរចេញពីស្រុកពោធិហ្ស្រី យើងបានទៅជំរាបលាមីងខែម គាត់បានឲ្យពរសព្វសាធុការដល់ខ្ញុំ

និងសុខ-សម្បូរ ឲ្យបានប្រកបនូវសេចក្ដីសុខសួស្ដី ហើយគាត់សង្ឃឹមថា នឹងបានឃើញខ្ញុំ ត្រឡប់ទៅលេងស្រុកពោធិហ្នស្រីនេះទៀតជាពុំខាន ។

ខ្ញុំក៏ឆ្លើយថា ខ្ញុំក៏មានបង្ឃឹមដូច្នោះជានិច្ចដែរ តែតាមពិត ខ្ញុំគ្មានសង្ឃឹមអ្វីបន្តិចបន្តួចសោះ ព្រោះអនាគតដ៏ឆាប់នេះ ខ្ញុំនឹងត្រូវចូលទៅក្នុងទ្រុងដែក ដែលគ្មានសង្ឃឹមថា នឹងមានថ្ងៃណាបានរួចខ្លួនចេញមកនៅខាងក្រៅសោះឡើយ ។

យើងបាននាំគ្នាចេញដំណើរពីភូមិពោធិហ្នស្រីនៅវេលាម៉ោង ៤ រសៀល ។ មីងផែមនាងសាមុត និងនាងយូរ៉េត ក៏បានជូនដំណើរយើងមកដែរ ។ យើងបានដើរតាមផ្លូវលំមាត់អូរបត់ឆ្វាត់ឆ្វែងអស់ពេលពីរម៉ោង ទើបបានមកដល់ផ្សារបាត់ដំបង ដែលយើងប្រមាណមើលទៅថាផ្លូវនេះ មានចម្ងាយប្រហែលជាងប្រាំបីគីឡូម៉ែត្រ ។

នៅបាត់ដំបង យើងបានទៅសំណាក់នៅសណ្ឋាគារ



មួយនៅក្បែរផ្សារ ។

អ្នកទាំងអស់គ្នាដែលមកជាមួយ សុទ្ធតែបានដឹងថា នាង យូរ៉េត និងខ្ញុំជាអ្វីនឹងគ្នា ។ គេបានបណ្ដោយពេលទុកឲ្យយើងនៅតែពីរនាក់ ដេកតែពីរនាក់នៅក្នុងបន្ទប់មួយ ។

ខ្ញុំចេះតែទុកបន្ទប់ជាទីកសាននៃសេចក្ដីសុខ ដែលចេះតែរឹតចូលសង្ឃឹម ៗ មកជានិច្ច ។ ខ្ញុំមានពេលត្រឹមតែមួយយប់ប៉ុណ្ណោះ ខ្ញុំដែលត្រូវបាននៅជិតស្និទ្ធនាង យូរ៉េត ជាទីស្នេហារបស់ខ្ញុំ ។ រាត្រីកាលរបស់យើងបានកន្លងទៅជាប់ដោយសេចក្ដីសោកសៅ ច្រើនជាងសេចក្ដីរីករាយ ។ នាងយូរ៉េត បានខំព្យាយាមរក្សានូវកំឡាំងចិត្តរបស់ខ្ញុំ ដោយពុំនិយាយអ្វីឲ្យខ្ញុំពិបាកចិត្តឡើយ តែពាក្យមួយឃ្លាដែលនាងប្រកាន់ខ្ជាប់នោះ គឺនាងនិយាយថា នាងពុំព្រមយកប្ដីអស់មួយជីវិត ។ នាងបានប្ដេជ្ញាចំពោះវត្ថុស័ក្តិសិទ្ធិទាំងឡាយថា នាងនឹងរក្សាខ្លួនទុកជាសម្បត្តិរបស់ខ្ញុំ តែម្នាក់ទាំងក្នុងជាតិនេះ

មិនជាតិខានមុខ ។

នាង យូរ៉េត បានជួយបញ្ចូលហេតុផលដល់ខ្ញុំថា ឪពុកម្ដាយតែងធ្វើការគ្រប់យ៉ាងជាផ្លូវល្អចំពោះកូន ។ ដូច្នេះ កូនត្រូវតែប្រតិបត្តិតាមឪពុកម្ដាយ ។ នាងបានរំឭកដល់សេចក្ដីល្អដែលខ្ញុំបានធ្វើចំពោះនាង ហើយដោយសារសេចក្ដីល្អនេះ នាងសុខចិត្តលះបង់ជីវិតទាំងមូលដើម្បីបូជាខ្ញុំ ។ ឯរូបនាងវិញនោះ នាងគ្មានបានធ្វើគុណប្រយោជន៍អ្វីដល់ខ្ញុំសោះ ។ ដោយសារការយល់យ៉ាងនេះ ទើបនាងពុំត្រូវការឲ្យខ្ញុំលះបង់អ្វីច្រើនជាងការដែលខ្ញុំបានធ្វើរួចមកហើយនោះឡើយ ។

នាង យូរ៉េត និយាយច្រើនជាងខ្ញុំ ព្រោះខ្ញុំដូចជាទាល់ប្រាជ្ញគេនិយាយស្ដីពុំរួច ។ ការប្រព្រឹត្តទៅនៃជីវិតប្រែប្រួលបានបិទមាត់ខ្ញុំពុំឲ្យនិយាយស្ដីអ្វីរួច ។ ឯការដែលនាងជូនដំណើរខ្ញុំមកដល់ពាក់កណ្ដាលផ្លូវដូច្នេះ ក៏ដូចជាដាក់ទោសយ៉ាងធ្ងន់មកលើរូបខ្ញុំ ព្រោះវាធ្វើឲ្យទឹកចិត្តរបស់ខ្ញុំសោប.



សេលៃសៃយ៉ាងខ្លាំង ។ នាងនឹងនៅតែសាបជះនូវសេចក្ដីស្នេហាមកលើរូបខ្ញុំ ខ្ញុំនឹងនៅតែមានចិត្តបង្អៀតបន្តល់ខ្លាំងឡើង ៗ នៅពេលជិតបែកគ្នា ។

រាត្រីនេះ ជារាត្រីទីបំផុតនៃសេចក្ដីសុខរបស់យើង ព្រោះនាងជូនដំណើរខ្ញុំមកត្រឹមនេះ ហើយព្រឹកឡើងយើងត្រូវបែកគ្នា ដោយខ្ញុំត្រូវធ្វើដំណើរទៅភ្នំពេញ នាង យូរ៉េត ត្រូវធ្វើដំណើរត្រឡប់ទៅស្រុកពោធិហ្ស៊ីវិញ ។

នៅពេលយប់ជ្រៅនាង យូរ៉េត អង្គុយសម្រក់ទឹកភ្នែក ។ ខ្ញុំគិតថា នាង យូរ៉េត ប្រហែលជាលួចសម្រក់ទឹកភ្នែកជាច្រើនមកពីថ្ងៃមុនហើយ ៗ នាងទំលាក់ពុំឲ្យខ្ញុំឃើញ តែយប់នេះនាងរកលាក់ពុំកើត ។ ទឹកភ្នែករបស់នាងបានធ្វើឲ្យខ្ញុំតឹងចិត្តនិងពិបាកចិត្តយ៉ាងខ្លាំង ។ ខ្ញុំបានឲ្យឈ្មោះរាត្រីនោះថា ជារាត្រីសោកស្នេហា ដែលខ្ញុំពុំអាចបំភ្លេចបានក្នុងជីវិតនេះ ៗ

យូរ ៗ យើងឮសូរមាន់រងាវម្ដង ។ មាត់មាន់រងាវនេះ

ពុំមែនការឆោតតាមពេលវេលាទេ តែមកពីយើងដេកពុំលក់រហូតដល់យប់ជ្រៅ ទឹកសន្សើមធ្លាក់ត្រជាក់សព្វាង្គកាយ ។ នាង យូរ៉េត ពុំបានឃ្លាតចេញពីដើមទ្រូងរបស់ខ្ញុំឡើយ ដែលមើលទៅហាក់ដូចជា ពួកកាយទាំងពីររលាយចូលគ្នាតែមួយ ។ ខ្យល់បក់រឹៗ ចូលតាមបង្អួច ផាប់ដោយអាកាសត្រជាក់មកជាមួយផង បានជំរុញយើងទាំងពីរនាក់ឱ្យរឹតរឹតតែរិតចូលជិតគ្នាថែមទៀត ។

– អូននៅមានសង្ឃឹមម្យ៉ាង ជាសេចក្តីសង្ឃឹមក្នុងជីវិតរបស់អូន ( នាង យូរ៉េត និយាយ )

– អូន យូរ៉េត សង្ឃឹមអ្វី ?

– អូនសង្ឃឹមថា សេចក្តីស្នេហាបរិសុទ្ធរបស់យើងនេះអាចបណ្តាលឱ្យអូនមានកូនជាមិនខាន – ប្រសិនបើបានកូនមែននោះ ការរស់នៅក្នុងជីវិតក៏នឹងបានធូរស្រាលឡើង ព្រោះជីវិតរបស់អូននឹងមិនស្ងាត់ស្ងៀមក្រៀមក្រំតែឯកឯង អូននឹង



បានកូនគ្រាន់បានជាគ្នា ហើយមុខជានឹងធូរទ្រូងខ្លះ បងបានទុកកូនឱ្យអូនក្នុងពេលអរុណជិតរះ ដែលមានមាន់រងាវឆ្លើយឆ្លងគ្នាផងឆ្ងាយ ហៅឱ្យព្រះអាទិត្យប្រញាប់រះឡើង ជួយបំភ្លឺផ្លូវឱ្យកូនយើង – អូនសុំឱ្យកូននេះល្អដូចជារស្មីនៃព្រះអរុណ ។

ទីបំផុត ពេលព្រះអរុណរះក៏មកដល់ អរុណនៃការកំណាចសាហាវ អរុណដែលរះឡើងដូចជាបំបែកយើងទាំងពីរឱ្យបែកឆ្ងាយពីគ្នា ។

ខ្ញុំគិតថា ខ្ញុំពុំអាចត្រឡប់មកជួបនាង យូរ៉េត វិញបានឡើយ ព្រោះកាលបើខ្ញុំទៅដល់ភ្នំពេញហើយ ប្រាកដអាពាហ៍ពិពាហ៍ក៏មុខជាវណ្ណកខ្ញុំជាប់ ។ ខ្ញុំត្រូវបិតនៅក្រោមការត្រួតត្រានៃស្ត្រី ដែលខ្ញុំពុំដែលមានមេត្រីចិត្ត មិនដែលស្គាល់និស្ស័យចិត្តថ្លើម ។ កាលបើពិធីមង្គលការបានធ្វើរួចផុតទៅ សេរីភាពជាទីស្នេហារបស់ខ្ញុំ ក៏នឹងអស់អាយុជីវិតតាំងពីពេលនោះទៅដែរ ។

យើងលាបែកគ្នានៅពេលអ្នកបូវ៉ែ ចេញ ។ ខ្ញុំក្រឡេកមើលទៅក្រោយវិញតាំងអាល័យ ។ ខ្ញុំបានឃើញនាងយូរ៉ែត និងអ្នកដែលជូនមកជាមួយ ឈរនៅត្រង់កន្លែងដដែល លើកដៃឡើងជាសញ្ញានៃការលាគ្នា ។ ខ្ញុំខំសំឡឹងមើលទាល់តែស្រវាំងភ្នែក ឃើញដូចជាផែនដីបានបែកញែកចេញពីគ្នាយ៉ាងឆ្ងាយ ក្លាយទៅជាសមុទ្រផុតកន្ទុយភ្នែក ... ខ្ញុំងាកមុខមកវិញ ក្នុងខណៈដែលបេះដូងបានស្រែកតាំងក្តីអាល័យថា :

" លាហើយស្នេហា "

x
x x

# ជំពូកទី ២

## វគ្គទី ៧

## ការក្បត់ជាតិរបស់ខ្ញុំ

នៅក្នុងការិយាល័យដ៏ធំទូលាយ តុបតែងដោយតុទូយ៉ាងទំនើប ៗ ឯកឧត្តម ឧត្តមសេនីយ ទេសរដ្ឋមន្ត្រីក្រសួងការពារប្រទេស កំពុងតែពិនិត្យសំណុំរឿងផ្សេង ៗ ដែលគរជាគំនរនៅលើតុរបស់ឯកឧត្តម ។ មួយស្របក់ ឯកឧត្តមបានចាត់ការអស់ ហើយក៏ក្រោកដើរចុះឡើង ក្រពាត់ដៃទៅក្រោយ ដូចជាកំពុងត្រិះរិះគិតសម្រេចការអ្វីធំមួយ ៗ ដំណើរដើរជាសក្ខីភាពនៃសតិទីនទ ទីងទំហរីងប៉ឹង ..., សភាពសក់ខ្មៅរួញ កាត់ឡុងសុងប៉ូកណា វែកសោរចំកណ្ដាល ជាគ្រឿងសំគាល់ពូជខ្មែរបុរាណមកពីកម្ពុជ ជាអ្នកចាស់ទុំ ។ ថ្ងាសទូលាយ សំគាល់ថា ជាអ្នកប្រាជ្ញមានចិត្តទូលាយ ។

ចិញ្ចើមក្រាស់ហើយធំ សំគាល់ថា ជាអ្នកក្លាហាន ។ ភ្នែកវែងឆ្ងាយ សំគាល់ថា ជាអ្នកមានចិត្តមេត្តា ។ រោមភ្នែកវែងហើយងើឡើងលើ សំគាល់ថា ជាអ្នកមានប្រាជ្ញាដោះខ្លួន ។ ច្រមុះខ្ពស់វែងធំ សំគាល់ថា ជាអ្នកចិត្តមុត ។ រង្វង់មាត់មានរឹមជុំវិញ ហើយញញឹមជាប់ សំគាល់ថា ជាអ្នកមានចិត្តទូលាយនិងចិត្តករុណា ។ ថ្គាមខ្លាំង ចង្កាក្រាយវែង សំគាល់ថា ជាជនមានបុណ្យនិងចិត្តក្លាហាន ។

ដើរចុះឡើងមួយស្របក់ ក៏ត្រឡប់ទៅអង្គុយនៅការិយាល័យវិញ ហើយហូតថតតុទាញយកក្រដាសមួយ មកឈ្ងោកពិនិត្យពិច័យ ហាក់ដូចជាមានវត្ថុអ្វីមួយ អាចស្រូបទាញខួរស្មារតីអារម្មណ៍របស់ឯកឧត្តមឲ្យសំឡឹងមើលស្ទើរតែមិនព្រិចភ្នែក ។ ក្នុងខណៈមួយរំពេចនោះ ឯកឧត្តមក៏បានងើបមុខឡើងដោយអាការៈអន្ទះអន្ទែង ព្រោះការពិបាកចិត្ត បែបទន្ទឹងចាំអ្វីមួយ ដែលឯកឧត្តមបានគម្រោង ។



នាឡិកាបានវាយម៉ោង ១០ ឯកឧត្តមចុចកណ្ដឹង លោកអនុសេនីយឯក សំរេច បានចូលមក ។

— ឃើញលោក ហង្ស-ចំរើន មកឬទេ ? ( ឯកឧត្តមបានសួរ)

— ប្របាទម្ចាស់ លោកវរសេនីយត្រី ហង្ស-ចំរើន អញ្ជើញមកហើយ លោកនៅខាងក្រៅ (អនុសេនីយឯក សំរេច បានឆ្លើយ)

— អញ្ជើញលោកចូលមក ។

លោកអនុសេនីយឯក សំរេច ក៏ចេញទៅអញ្ជើញលោកវរសេនីយត្រី ហង្ស ចំរើន ។

ឯកឧត្តម ចិតបារី រង់ចាំដោយទឹកមុខញញឹម ដើម្បីទទួលមេក្រុមចារកម្ម ដែលត្រូវនាំរូបកាយ ទាហានមួយរូបមកជូនឯកឧត្តមស្គាល់មុខ ។

ក្នុងពេលជាបន្ទាប់នោះ លោកវរសេនីយត្រីហង្ស-ចំរើន

ក៏បានចូលមកដោយបាននាំតាំងសហការីរបស់លោកម្នាក់ គឺរូបខ្ញុំ ទៅជួបឯកឧត្តមទេសរដ្ឋមន្ត្រី ។

លោកឧត្តមសេនីយ ទទួលលោកវរសេនីយត្រី និងខ្ញុំ យ៉ាងកក់ទាក់ ដោយទឹកមុខញញឹម ។ ក្រោយពេលបានគោរពចំពោះឯកឧត្តមនិងអង្គុយក្នុងទីដ៏សមគួរហើយ លោកវរសេនីយត្រី ហង្ស-ចំរើន ក៏បានចាប់ផ្តើមនិយាយដំរាបលោកឧត្តមសេនីយ ពីគុណសម្ប័ទរបស់ខ្ញុំ ។

— ឯកឧត្តម ! (លោកវរសេនីយត្រី ហង្ស-ចំរើន និយាយ) សហការីរបស់ខ្ញុំប្របាទម្ចាស់មួយរូបនេះឈ្មោះ... (ឈ្មោះខ្ញុំ) ដែលខ្ញុំប្របាទម្ចាស់បានជ្រើសរើសបានពីចំណោមនាយទាហានជាច្រើន ព្រោះជានាយទាហានដែលបានធ្វើឲ្យខ្ញុំប្របាទម្ចាស់ទុកចិត្តទុកថ្លើមអស់ពីពោះ ។

— ខ្ញុំក៏បានសង្កេតឃើញដូចលោកដែរ (ឯកឧត្តមមានប្រសាសន៍ហើយដើរមកអង្អែលស្មាខ្ញុំ) លោកស័ក្តិពីរ ! លោក



ជាយុវជនខ្មែរមួយរូប ដែលស្ម័គ្រចិត្តចូលមកបំរើផែនដី លោកជានាយទាហានដ៏ប្រសើរ មានចរិយាទន់ភ្លន់ មានបុគតា ដែលគួរឲ្យខ្ញុំទុកចិត្ត សមដូចពាក្យដែលលោកវរសេនីយត្រី បាននិយាយប្រាប់ខ្ញុំមែន ខ្ញុំសុំសំដែងនូវសេចក្តីសរសើរចំ-ពោះលោក ហើយខ្ញុំសង្ឃឹមថា មានតែលោកម្នាក់ទេដែលអាចបំពេញនូវបេសកកម្មដ៏ពិបាកជូនប្រទេសជាតិឲ្យសម្រេចបាន ។

លោកឧត្តមសេនីយ ដឹកដៃខ្ញុំឲ្យដើរទៅអង្គុយជិតហើយ លោកសំឡឹងមើលខ្ញុំស្ទើរតែពុំព្រិចភ្នែក ។

— លោក ! (លោកឧត្តមសេនីយមានប្រសាសន៍ទៅទៀត) រឿងដែលខ្ញុំត្រូវនិយាយប្រាប់លោកឥឡូវនេះ ជារឿងមានសារៈសំខាន់ជាទីបំផុត ដែលលោកត្រូវបិទបាំងឲ្យជិត ព្រោះជារឿងអាថិកំបាំង ដែលទាក់ទងនឹងជីវិតប្រទេសជាតិមាតុភូមិ ។

គ្រាន់តែឮប្រសាសន៍លោកឧត្តមសេនីយ៍ដូច្នេះ ខ្ញុំដូចជាភ័យបន្តិច អរបន្តិច ៗ ខ្ញុំអង្គុយនៅស្ងៀម ឥតឆ្លើយថាអ្វី ៗ ឯកឧត្តមសំឡឹងមើលមុខខ្ញុំម្ដងទៀត ដែលធ្វើឲ្យខ្ញុំឱនមុខចុះ ព្រោះពុំហ៊ានឲ្យប៉ះក្រសែភ្នែករបស់ឯកឧត្តម ។

— លោកស័ក្តិពីរ ! សុំលោកផ្ទៀងត្រចៀកចាំស្ដាប់ខ្ញុំ ខ្ញុំនឹងសួរលោកនូវបញ្ហាមួយ ដែលពុំគួរដល់នាយទាហានដែលមានឋានៈខ្ពង់ខ្ពស់ សមជាអ្នកទទួលនូវសំលៀកបំពាក់ជាឯកសណ្ឋានរបស់កងយោធពលខេមរភូមិន្ទ ចង់ឮនូវសំនួរយ៉ាងនេះឡើយ ... ( ឯកឧត្តមឈប់នៅស្ងៀមបន្តិច ហាក់ដូចជាចង់សង្កេតមើលអាកប្បកិរិយារបស់ខ្ញុំ ហើយក៏ចាប់មានប្រសាសន៍តទៅទៀត) លោកស័ក្តិពីរ ! ខ្ញុំចង់សួរលោកថា តើលោកអាចក្បត់ប្រទេសជាតិមាតុភូមិរបស់លោកបានដែរឬទេ ?

ខ្ញុំដូចជាភ្ញាក់ខ្លួនព្រើត ៗ បេះដូងរបស់ខ្ញុំ ស្ទើរតែឈប់



លែងដើរការ ៗ ទឹកមុខរបស់ខ្ញុំឡើងស្លេកស្លាំងមួយរំពេច ៗ ខ្ញុំនឹកបន្តិចហើយជាប់ចិត្តសួរទៅឯកឧត្តមវិញ :

— សុំទានមេត្តាអភ័យទោសទានប្រោស ! ខ្ញុំប្របាទម្ចាស់ដូចជាពុំទាន់យល់ដល់ន័យនៃសំនួររបស់អ្នកប្របាទម្ចាស់សោះទានប្រោស ...

លោកឧត្តមសេនីយ៍ និង លោកវរសេនីយ៍សំឡឹងមើលមុខគ្នាទៅវិញទៅមកដោយអាការញញឹម ហាក់ដូចជាពេញចិត្តនឹងសភាពដែលខ្ញុំពុំយល់ដល់សំនួរនោះ ។

— លោកស័ក្តិពីរ ! (លោកឧត្តមសេនីយ៍មានប្រសាសន៍ដោយអអការម៉ឺងម៉ាត់) លោកបានឮនូវសំនួររបស់ខ្ញុំហើយមែនឬទេ ? ការដែលលោកវរសេនីយ៍និងខ្ញុំ ហៅលោកមកជួបនេះ គឺដើម្បីសួរបញ្ជាក់លោកយ៉ាងខ្លីថា លោកអាចក្បត់មាតុភូមិលោកបានដែរឬទេ តែប៉ុណ្ណោះ ...

ដោយសារខ្ញុំនៅស្ងៀម ពុំដឹងជាឆ្លើយដូចម្ដេច

លោកឧត្តមសេនីយ៍ក៏មានប្រសាសន៍ជូនឡើងទៀតថា ក្បត់ដើម្បីបំរើប្រទេសជាតិឲ្យបានប្រសើរជាងមុខការរបស់លោកសព្វថ្ងៃ ...

— សូមមេត្តាអត់ទោសដល់ខ្ញុំប្របាទម្ចាស់ផងចុះទានព្រោស! (ខ្ញុំឆ្លើយដោយទឹកមុខដែលសំដែងនូវការពុំយល់) ខ្ញុំប្របាទម្ចាស់ពុំដែលបានជួបប្រទះនឹងសេចក្ដីស្នើយ៉ាងនេះសោះទានព្រោស — ខ្ញុំប្របាទម្ចាស់ពុំដែលបានគិតគូពីរឿងក្បត់ប្រទេសជាតិយ៉ាងនេះសោះ ...

— លោកសក្ដិពីរ! (ឯកឧត្ដមមានប្រសាសន៍ដោយទឹកមុខញញឹម) ការជួបប្រទះនឹងបញ្ហាចំឡែកបែបនេះ ជាការនាំឲ្យលោកងឿងឆ្ងល់មែនហើយ តែសុំលោកចាំស្ដាប់សេចក្ដីពយករណ៍របស់ខ្ញុំឲ្យបានច្បាស់លាស់ តាមស្ថានការណ៍ពិត ... ខ្ញុំនឹងបំភ្លឺលោកត្រង់ចំណុចសំខាន់ខ្លះ នៃបេសកកម្មដែលខ្ញុំតម្រូវឲ្យលោកបំពេញ ... រួចហើយត្រូវ



លោកប្រាប់មកខ្ញុំវិញថា តើលោកអាចបំពេញនូវបេសកកម្មនោះបានឬក៏ពុំបានតែប៉ុណ្ណោះ ...

— ប្របាទម្ចាស់ :

— លោក អស់ពេលជាងមួយខែមកហើយ ដែលអគ្គសេនាធិការយោធពលខេមរភូមិន្ទយើង បានទទួលដំណឹងថា ពួក ដាប-ឈួន រួមគំនិតជាមួយ សម-សារី និង សឺង ង៉ុកថាញ់ ក្បត់ប្រទេសជាតិ ដោយមានអាមេរិក យួន និងសៀមនៅក្រោយខ្នង ពួកខ្មាំងបានប្រុងប្រៀបបំបែកប្រទេសខ្មែរជាពីរ តាមគំរោងការរបស់អាមេរិកាំង ដោយដណ្ដើមយកខេត្តសៀមរាបកំពង់ធំ និងបាត់ដំបង ឲ្យនៅក្នុងការត្រួតត្រារបស់វា ហើយវាប្រកាសខ្លួនធ្វើជាខ្មែរសេរី ដើម្បីវាយលុកចូលមកភ្នំពេញ — ក្រុមបាតកម្មរបស់វា មានតែបំណងមុះមុត ដើម្បីលួចយកផែនការសម្ងាត់របស់យើងឲ្យបាន ពួកក្បត់បានទិញជនខ្លះឲ្យធ្វើការឲ្យវា ដោយធ្វើ

ពលិកម្មគ្រប់យ៉ាងក្នុងរឿងនេះ ឥឡូវខ្ញុំទើបបានទទួលដំណឹងពីចារកម្មរបស់យើងដែលបានតាមដានពួកក្បត់ថា មាននាយទាហានខ្មែរម្នាក់ បំរើនិងលក់ផែនការសម្ងាត់របស់យើង ឲ្យពួកក្បត់តម្លៃសាមសិបម៉ឺនរៀល .

— បើអញ្ចឹង អ្នកប្របាទម្ចាស់នឹងតម្រូវឲ្យខ្ញុំប្របាទម្ចាស់ដើរតួជាជនទុរយសនោះ ឬ ពានព្រោស ?

ឯកឧត្តមទេសរដ្ឋមន្ត្រី ងក់ក្បាលញញឹម ដោយអាការពេញចិត្ត ហើយមានប្រសាសន៍ថា :

— ត្រូវហើយ ! លោកស័ក្តិពីរ ! ... ជនដែលក្បត់ជាតិនោះ ពុំមែនក្រៅពីមនុស្សដែលយើងទុកចិត្តទុកថ្លើមនោះទេ វាសនានៃប្រទេសជាតិបានតម្រូវឲ្យយើងទុកចិត្តលើរូបលោក ដែលស្រឡាញ់ប្រទេសជាតិពិតប្រាកដ ... ជនក្បត់ជាតិដែលយើងត្រូវគិតដល់នេះ គឺរូបលោក .. លោកស័ក្តិពីរ លោកពុំចាំបាច់មកជួបនឹងខ្ញុំទៀតទេ ការទាំងអស់ខ្ញុំបាន



ប្រគល់ឲ្យលោកវរសេនីយត្រីរួចអស់ហើយ – បើលោកបញ្ជាយ៉ាងណា សុំឲ្យធ្វើតាមចុះ – ខ្ញុំជឿថា រូបលោកហ្នឹងឯងហើយដែលត្រូវបានទទួលប្រាក់សាមសិបម៉ឺនរៀល ជាថ្លៃនឹងផែនការសម្ងាត់របស់យើង – ការក្បត់របស់លោក នឹងប្រែក្លាយទៅជាកិច្ចប្រសើរបំផុតក្នុងការបំរើប្រទេសជាតិមាតុភូមិ ... ម៉េចលោកយល់ ឬ ទេ ?

— ខ្ញុំប្របាទម្ចាស់ដូចជាពុំយល់ ហើយខ្ញុំប្របាទម្ចាស់ដូចជាធ្វើពុំកើតផង –

— ខ្ញុំក៏យល់ដល់ចិត្តថ្លើមលោកណាស់ដែរ (លោកវរសេនីយត្រី និយាយកាត់ឡើង) សុំលោកអនុញ្ញាតឲ្យខ្ញុំរំលឹកលោកបន្តិចចុះ លោកធ្លាប់បានដឹងហើយថា ទាហានមានកាតព្វកិច្ចត្រូវតែទទួលប្រតិបត្តិតាមបញ្ជារបស់នាយចៅហ្វាយ ដោយគ្មានការជជែក ...

— រឿងនោះខ្ញុំបាទ (ខ្ញុំនិយាយនឹងលោកវរសេនីយ

ពុំមែនជាមួយឯកឧត្តមទេ ) ខ្ញុំបានដឹងហើយ តែទាហានត្រូវតែស្មោះត្រង់នឹងប្រទេសជាតិ ...

– ត្រូវហើយលោកស័ក្តិពីរ ! ( ឯកឧត្តមទេសរដ្ឋមន្ត្រីមានប្រសាសន៍កាត់ឡើង ) តែពេលនេះជាបេសកកម្មដ៏ប្រយោជន៍ជាតិកិច្ចការឯទៀតៗទាំងអស់ ពិតណាស់ហើយ ខ្ញុំក៏ទទួលស្គាល់ថា ការក្បត់ជាតិជាការខុសនឹងផ្លូវច្បាប់ ហើយសំខាន់បំផុត គេក៏ពុំដែលបញ្ចោញតាំងពីមុនឲ្យទាហានណាម្នាក់ក្បត់មាតុភូមិរបស់ខ្លួនទេ ទោះបីកិច្ចការនោះប្រសើរយ៉ាងណាក៏ដោយ ... ខ្ញុំដឹងហើយថា ទាហានទាំងអស់ សុទ្ធសឹងតែស្ម័គ្រចិត្តធ្វើពលិកម្មចេញទៅប្រយុទ្ធនឹងខ្មាំងនៅសមរភូមិមិនខ្លាចស្លាប់ ព្រោះគេយល់ថា ជាការប្រសើរជាងការក្បត់ជាតិ តែពលិកម្មពិសេសដែលខ្ញុំត្រូវឲ្យលោកបំពេញនេះ ក៏ព្រោះយល់ឃើញថា មានតែលោកម្នាក់ប៉ុណ្ណោះទេ ដែលជាវរជន អាចបំពេញនូវពលិកម្ម



ដែលនេះ ឲ្យសម្រេចបាន ...

បរិយាកាសបានស្ងប់ស្ងាត់មួយភ្លែត ដោយខ្ញុំពុំដឹងជាឆ្លើយដូចម្ដេច ។ លោកឧត្តមសេនីយបានចាប់ផ្ដើមមានប្រសាសន៍ឡើងទៀត ដោយពាក្យសំដីបង្គាប់បញ្ជាយ៉ាងដាច់ខាត ៖

លោកស័ក្តិពីរ ! លោកត្រូវតែធ្វើតាមខ្ញុំ ... លោកត្រូវកុះតារការពិបាកនេះ ដើម្បីឲ្យគ្រោងការយើងបានសម្រេចផល – ខ្ញុំសុំបញ្ជាក់ប្រាប់លោកថា យើងត្រូវការបំភាន់ខ្មាំង គឺយើងចង់ធ្វើឲ្យឯកសារនៃផែនការសម្ងាត់ ដូចជាត្រូវលបលួចយកបាន ដោយការប៉ិនប្រសប់នៃខាយតាហានម្នាក់តែប៉ុណ្ណោះ – រូបខ្ញុំនិងលោកវរសេនីយត្រី បានគិតគ្រោងការនេះឡើងហើយ យើងក៏បានគិតដល់រូបលោកមុនគេ – ខ្ញុំសង្ឃឹមហើយជឿជាក់ថា លោកទំនងពុំធ្វើឲ្យយើងស្ដាយនូវការជ្រើសរើសរបស់យើងទៅលើរូបលោកនេះទេ ...

សភាពស្ងប់ស្ងៀម បានកើតឡើងទៀត ... ខ្ញុំបាន ដកដង្ហើមវែង ៗ ហើយសម្លឹងមើលផ្ទៃឥដ្ឋពណ៌ក្នុងការិយា-ល័យដោយសភាពចិត្ត ដែលពោរពេញដោយការគន្ទះកតាមមនោសញ្ចេតនាពីរចំណែកគឺ មួយចំណែក ខ្ញុំនឹកត្រេកអរព្រួច ព្រោះគិតថា នាយហៅហ្វាយបានទុកចិត្តលើរូបខ្ញុំ មួយចំណែកទៀត ខ្ញុំនឹកស្អប់ខ្ពើមចំពោះពាក្យថាក្បត់ជាតិនេះជាខ្លាំង ថ្វីបើការក្បត់នេះ ជាការធ្វើតាមបង្គាប់បញ្ជាពីហៅហ្វាយនាយក៏ដោយ ...

ប៉ុន្តែវិន័យទាហានបានតម្រូវឲ្យប្រតិបត្តិតាមបញ្ជារបស់នាយហៅហ្វាយ ... គិតដូច្នេះទ្រូងខ្ញុំឡើងតឹងណែនស្ទើរប្រេះ ... ខ្ញុំនឹកក្នុងចិត្តថា ខ្ញុំត្រូវតែទទួលគោរពតាមបង្គាប់បញ្ជានាយហៅហ្វាយទាំងពីររូបនេះ បើពុំដូច្នោះទេ ខ្ញុំនឹងត្រូវទទួលទោសព្រោះប្រកែក ...

✠ ✠
✠



បរិកាសតានតឹង ហាក់ដូចជាបានធូរស្រាលវិញបន្តិចក្នុងខណៈដែលលោកវរសេនីយត្រី លាឯកឧត្តមទេសរដ្ឋមន្ត្រី ហើយនាំខ្ញុំត្រឡប់ទៅការិយាល័យទី ២ វិញ ។ ប៉ុន្តែខ្ញុំក៏ពាប់ព្រួយចិត្តមួយជាន់ទៀត ព្រោះលោកវរសេនីយត្រីបានហៅខ្ញុំឲ្យអង្គុយទល់មុខនឹងលោក ហើយដកថតតុទាញយកកញ្ចប់ក្រដាសសមួយកញ្ចប់ហុចមកឲ្យខ្ញុំ ព្រមទាំងពាក្យបញ្ជាយ៉ាងដាច់ខាតថា :

លោកសក្តិពីរ! នេះ ប្រាក់ដប់ម៉ឺនរៀល ... លោកត្រូវយកប្រាក់នេះទៅលេងល្បែងឲ្យទាល់តែចាញ់អស់ក្នុងថ្ងៃនេះ ហើយស្អែក លោកត្រូវមកជួបនឹងខ្ញុំនៅពេលរសៀល តែបើមិនទាន់ចាញ់អស់ប្រាក់ទេ កុំអាលមកជួបនឹងខ្ញុំ ...

— ព្រះតេជគុណ! ខ្ញុំបាទពុំហ៊ានទទួលយកទេបាទប្រោស (ខ្ញុំឆ្លើយឡើងទាំងភិតភ័យ) ព្រោះមួយជាតិនេះ ខ្ញុំបាទពុំចេះលេងល្បែងទាល់តែសោះបាទប្រោស ...

— ហ៊ឺយកទៅ ! ( លោកវរសេនីយត្រីបញ្ជាដោយបង្ខិតបង្ខំ ) នេះជាបញ្ជាការដាច់ខាតរបស់ខ្ញុំ . . .

ខ្ញុំត្រូវទទួលយកប្រាក់ដប់ម៉ឺនរៀលនេះទាំងប្រថុយ ហើយក៏គំនាប់លាលោកវរសេនីយត្រី ចេញពីការិយាល័យ ត្រឡប់ទៅផ្ទះវិញ . . .

ខ្ញុំដូចជាគេគិតពុំយល់ថា ហេតុអ្វីគឺឯកឧត្តមទេសរដ្ឋមន្ត្រី និងលោកវរសេនីយត្រីបញ្ជាឲ្យខ្ញុំក្បត់ជាតិ ? មិនតែប៉ុណ្ណោះសោត លោកវរសេនីយត្រីបានឲ្យប្រាក់ខ្ញុំដប់ម៉ឺនរៀលយកទៅលេងល្បែងស៊ីសងដោយមានបញ្ជាថា បើមិនទាន់ចាញ់អស់កុំអាលត្រឡប់ទៅជួបនឹងលោកវិញ ។ រឿងនេះ ប្រែសេចក្តីថាដូចម្តេច ? បើខ្ញុំប្រតិបត្តិតាមបញ្ជានេះទៅ តើកិត្តិយសនាយទាហាននៅឯណា ? ប៉ុន្តែវិន័យទាហានបានតម្រូវឲ្យទាហានប្រតិបត្តិតាមបង្គាប់បញ្ជារបស់នាយចៅហ្វាយ . . . ។

ល្ងាចថ្ងៃនេះ ខ្ញុំបានចូលខ្លួនទៅក្នុងវង់ល្បែងស៊ីសង



ក្នុងគេហដ្ឋានមួយដោយសម្ងៀតបំពាក់ស៊ីវិល ។ តាំងពីកើតមក ខ្ញុំពុំដែលលេងល្បែងស៊ីសងពាល់តែសោះ តែខ្ញុំត្រូវតែប្រថុយលេងតាមបញ្ជារបស់នាយចៅហ្វាយ . . . ពាក្យថាល្បែងស៊ីសង ដូចជាសមសួនណាស់ ព្រោះវាមានស៊ីមានសង . . . ខ្ញុំបានរើសល្បែងមួយបែបដែលស្រួល គឺប៉ូ . . . ខ្ញុំពុំបានបង្អង់ឲ្យខាតពេលឡើយ ខ្ញុំចាប់ផ្តើមដាក់ដៃដំបូងប្រាំម៉ឺនរៀល . . . ពួកអ្នកលេងទាំងអស់សម្លឹងមើលមុខខ្ញុំដោយការគោតក្រែង តែវាជាគ្រោះល្អសំរាប់ខ្ញុំ ព្រោះគេបានស៊ីខ្ញុំអស់ប្រាំម៉ឺនរៀលនេះ . . . ការដែលខ្ញុំចាញ់ហើយខ្ញុំថាជាគ្រោះល្អនោះ គឺព្រោះខ្ញុំពុំចង់លេងពាល់តែសោះ ហើយនៅពេលលេងនេះ ខ្ញុំចង់ឲ្យតែឆាប់ចាញ់អស់ប្រាក់ ដើម្បីឲ្យឆាប់បានត្រឡប់ទៅផ្ទះវិញ ។

នៅថ្ងៃទីពីរ ខ្ញុំដាក់ប្រាំម៉ឺនរៀលទៀត ។ គ្រោះកាចក៏បានកើតឡើងដល់រូបខ្ញុំ ព្រោះខ្ញុំត្រូវចំកៅ៩ ហើយមេត្រូវ

សងខ្ញុំ ដប់ប្រាំម៉ឺនរៀល ... ឥឡូវខ្ញុំមានប្រាក់ម្ភៃម៉ឺនរៀល គឺច្រើនជាងមុនមួយជាពីរ ។ ខ្ញុំបានសួរមេថា អាចឲ្យខ្ញុំចាក់ទាំងអស់ដែរឬអ្វី? គេឆ្លើយថា គេអនុញ្ញាតឲ្យដាក់តែដប់ម៉ឺនរៀលប៉ុណ្ណោះ ។ ដូច្នេះខ្ញុំត្រូវនៅសល់ប្រាក់ពាក់កណ្ដាល ។ នៅថ្ងៃទីបីនេះ មេស៊ីអស់ ...

នៅថ្ងៃទីបួននិងទីប្រាំ ខ្ញុំបានរំលែកប្រាក់ដែលនៅសល់ចាក់ម្ដងប្រាំម៉ឺនរៀល តែត្រូវមេស៊ីទាំងអស់ ដែលមើលទៅសមនឹងពាក្យដែលគេឲ្យឈ្មោះថាមេមែន ...

ខ្ញុំបានត្រឡប់ទៅផ្ទះវិញ ក្រោមសញ្ញាថា ចាញ់ធួ ។ ថ្ងៃនេះពេញមួយថ្ងៃ ខ្ញុំដូចជារសេះរសោះអស់កំឡាំងជាខ្លាំង រកធ្វើអ្វីពុំកើត ។ ក្នុងចិត្ត ខ្ញុំគិតមួយម៉ឺនមួយសែនជំពូក តែដូចជាគ្មានបានការអ្វីសោះ ព្រោះខ្ញុំនៅតែពុំយល់ដល់បញ្ជាការរបស់ឯកឧត្ដម ឧត្ដមសេនីយ និង លោកវរសេនីយត្រី ហង្ស-ចំរើន ថា ហេតុអ្វីក៏លោកទាំងពីរបញ្ជាឲ្យខ្ញុំធ្វើដូច្នេះ?...



លុះពេលព្រឹកនៃថ្ងៃមួយទៀត ខ្ញុំក៏បានរៀបចំខ្លួនប្រាណចូលទៅជួបនឹងលោកវរសេនីយត្រី ហង្ស-ចំរើន ។

ក្រោយពេលបានធ្វើគារវកិច្ចរួចហើយ ខ្ញុំក៏បានរាយការណ៍ជំរាបលោកវរសេនីយត្រី ថា :

— ព្រះតេជ-គុណ ! ខ្ញុំបានប្រតិបត្តិតាមបញ្ជាការរបស់ព្រះតេជ-គុណ រួចស្រេចអស់ហើយពានព្រោស ...

— ល្អហើយលោកស័ក្ដិពីរ ! (លោកវរសេនីយត្រីនិយាយដោយទឹកមុខញញឹម) ខ្ញុំសុំសំដែងនូវអំណរគុណចំពោះលោកជាច្រើន ដែលលោកចេះប្រតិបត្តិតាមបញ្ជាការរបស់ខ្ញុំ ឲ្យបានសំរេចដោយរៀបរយយ៉ាងនេះ - សុំអញ្ជើញអង្គុយលោកស័ក្ដិពីរ ...

ខ្ញុំបានសំរុតខ្លួនចុះអង្គុយលើកៅអីមួយ ដែលបិតនៅទល់មុខនឹងលោក ។ លោកបានដកយកស្រោមសំបុត្រមួយហុចមកឲ្យខ្ញុំ ព្រមទាំងនិយាយថា :

— លោកសក្តិ! នេះ ជាឯកសារពិសេស ដែលលោកត្រូវមានបេសកកម្មបំពេញមួយជាន់ទៀត . . .

— ព្រះតេជ-គុណ! ការដែលព្រះតេជ-គុណ បានឲ្យកិត្តិយសដល់រូបខ្ញុំបាទ ដោយទុកឃើញរូបខ្ញុំបាទមុនគេ ក្នុងការបំពេញនូវបេសកកម្មដ៏ពិបាកនោះ តើព្រះតេជ-គុណឲ្យខ្ញុំបាទនាំយកឯកសារពិសេសនេះទៅណា បានព្រោស . . . ?

— ចាំស្តាប់ខ្ញុំ លោកសក្តិ! ខ្ញុំនឹងអធិប្បាយប្រាប់លោកពីបេសកកម្មនេះ (លោកបិតបារីហើយនិយាយតទៅទៀត) នៅពេលដែលលោកចេញពីនេះទៅ លោកនឹងឃើញឡានតាក់ស៊ីមួយពណ៌ប្រផេះដែលមានលេខ ១០០.០៦៤ ចតនៅស្ពៀម ដោយមានអ្នកបើកបរម្នាក់អង្គុយកាន់ចង្កូតចាំ អ្នកបើកបរនេះ ជាភ្នាក់ងារសម្ងាត់លេខ ៨ របស់យើង ហើយដែលក្រុមយើងបានប្រគល់ឲ្យគាត់ការសម្ងាត់ដែរ — ពេលដើរទៅដល់ លោកត្រូវឡើងជិះឡានភ្លាមដោយមិនបាច់សាកសួរអ្វី



ពីគេ — គេនឹងដឹកនាំលោកធ្វើដំណើរត្រង់ទៅកាន់ខេត្តសៀមរាបភ្លាមដែរ លោកទៅនៅសៀមរាបចាំស្តាប់ទូរលេខបញ្ជាការអំពីខ្ញុំ ដែលតម្រូវឲ្យលោកត្រឡប់មកភ្នំពេញវិញ កាលបើបានទទួលទូរលេខបញ្ជាហើយ លោកត្រូវចេញដំណើរមកពេលយប់នៅតាមផ្លូវពីសៀមរាបមកកំពង់ធំ លោកនឹងត្រូវជួបនឹងចារបុរសរបស់ដាប-ឈួន ម្នាក់នៅត្រង់កន្លែងណាមួយមិនកំណត់ ដែលអ្នកបើកបរឡានតាក់ស៊ីរបស់លោក បានដឹងសញ្ញារួចស្រេចអស់ហើយ — លោកគ្រាន់តែចាំធ្វើតាមពាក្យណែនាំរបស់អ្នកបើកឡាននេះ គឺជាការស្រេចទៅហើយ តែសុំលោកកុំភ្លេចខ្លួនថា លោកត្រូវដើរតួជានាយទាហានម្នាក់ដែលអស់សង្ឃឹម ហើយបានសម្រេចចិត្តជាស្រេចថា នៅរង់ចាំតែការសល្អហុចឲ្យប៉ុណ្ណោះ លោកហ៊ានធ្វើការអ្វីគ្រប់យ៉ាងរហូតដល់ហ៊ានក្បត់ជាតិដើម្បីប្តូរយកប្រាក់ណាលោក . . .

ខ្ញុំបានយកស្រោមសំបុត្រពណ៌សដែលមានបោះត្រាបិទ

ផ្ទិតដោយកាកអាចម៍ល័ក្ខដើម្បីបង្កប់ឯកសារពិសេសដែលមានតម្លៃស្មើនឹងប្រទេសមួយនៅខាងក្នុងនោះ សៀតនៅក្នុងហោប៉ៅអាវ ហើយក៏បិទឡេវអាវជិតទៅវិញ ។

— សុំគោរព ! សុំលាព្រះតេជ-គុណសិនហើយបាន ព្រោស . . .

— អើ ! អញ្ជើញទៅចុះលោកសក្តិពីរ !(លោកវរសេនីយត្រី ហង្ស-ចំរើន និយាយដោយទឹកមុខញញឹម ព្រមទាំងចាប់ដៃខ្ញុំលាក់យ៉ាងណែន ដែលជាសញ្ញាមួយប្រាប់ឲ្យដឹងថា លោកបានផ្ញើសេចក្តីទុកចិត្តលើរូបខ្ញុំយ៉ាងធំ) សុំលោកអញ្ជើញទៅឲ្យបានសម្រេចគ្រប់យ៉ាង ប្រទេសជាតិត្រូវការផ្ញើនូវសេចក្តីទុកចិត្តទាំងស្រុងលើរូបលោក សុំឲ្យលោកមានជោគជ័យក្នុងបេសកម្មពិសេសនេះ . . . . . ។

## វគ្គទី ៨

# ស្ត្រីជាសត្រូវ

នាងជម្ពូលាពជ្រ ជាកញ្ញាមួយរូបមានអាយុប្រមាណ ២០ ឆ្នាំ ។ ប្រសិនបើគេបោលភ្នែកក្រឡេកមើលនាងដោយការសង្កេតពិនិត្យ គេមុខជាដឹងថា នាងជាស្ត្រីកូនកាត់ ព្រោះពណ៌សម្បុរសាច់ឈាមរបស់នាងមិនខុសគ្នា ពីស្រីកូនកាត់ចិនខ្មែរប៉ុន្មាន ។ នាងមានផ្ទៃមុខមូលទ្រវែងដូចពងមាន់ ។ ខ្ទង់ច្រមុះមានចុងស្រួច បបូរមាត់ស្តើងមានពណ៌ក្រហមស្រស់ ភ្នែកទាំងគូខ្មៅរលោងស្រិលដូចនិល ដុះក្រោមរោមចិញ្ចើមដ៏តូចនិងខ្វង់ក្ងូរលើបដូចស្លាបចំកេម បានធ្វើផ្ទៃមុខរបស់នាង ឲ្យមានសម្រស់គួរជាទីចាប់ចិត្តនៃបុរសដែលបានឃើញ ។ នាងទុកសក់វែងធ្លាក់ចុះទៅបញ្ចោសអង្កែលស្មា ដែលមានពណ៌សទ្រលុកទ្រលន់ដូចភ្លុក

ដីរ ៗ នាងចូលចិត្តពាក់អាវក្រលកធំបញ្ចេញទូរសាច់ទ្រូង ដ៏សម្ញឹង ដែលធ្វើឲ្យបុរសមានការសំរើបចិត្តជាខ្លាំង កាលបើបានឃើញរូបនាងហើយ ។

ពិតណាស់នាងធរីពុំមែនជានារីខ្មែរសុទ្ធសាធទេ ។ ឪពុកនាងជាខ្មែរសុទ្ធ ហើយត្រូវជាបងប្អូនរបស់ឈ្មួ ឆ មួលពេជ្រ ឯម្តាយនាងជាយួនសុទ្ធ ។ នាងបានរៀនសូត្របេះជ្រៅជ្រះណាស់ដោយបញ្ញវ័ន្តឆ្លាត តាំងពីឪពុកនាងបានពាក់ស័ក្តិតារក្តិតង់ទីពិ ជាប - ឈ្មួ ឆ ។

នៅពេលដែលខ្ញុំត្រូវទៅប្រតិបត្តិការនៅខេត្តសៀមរាប តាមបញ្ជាការរបស់អគ្គសេនាធិការយោធពលខេមរភូមិន្ទនោះ ខ្ញុំបានស្គាល់នាងធរីនេះ ដោយសារមិត្តភក្តិម្នាក់ណែនាំឲ្យស្គាល់ ។ ក្នុងសប្តាហ៍ដំបូងដែលខ្ញុំបានឈានជើងចូលទៅកាន់ដីសៀមរាបនោះ ខ្ញុំបានស្គាល់នាងហើយកប់គានជិតជិតស្និទ្ធស្នាលនឹងគ្នាដូចជាធ្លាប់ស្គាល់មកយូរហើយ ។ ប៉ុន្តែ



ការកប់គានជិតជិតស្និទ្ធស្នាលនេះ ពុំមែនបានសេចក្តី ថាខ្ញុំស្រឡាញ់នាង ឬ ជាប់ចិត្តជាប់ថ្លើមនឹងនាងឡើយ ។ ខ្ញុំស្រឡាញ់នាងធរីដូចម្តេចកើត បើខ្ញុំនៅតែនឹកស្រមៃឃើញនាង យូរ៉េត របស់ខ្ញុំនៅជាប់នឹងភ្នែកជានិច្ច គ្មានពេលភ្លេចពេលរសាយដូច្នេះ បេះដូងរបស់ខ្ញុំដែលមានតែមួយនេះ ខ្ញុំបានប្រគល់ឲ្យនាង យូរ៉េត រួចទៅហើយ ខ្ញុំគ្មានបេះដូងណាទៀតសំរាប់ប្រគល់ឲ្យនាងធរីឡើយ ម្ល៉ោះហើយការជិតជិតស្និទ្ធស្នាលគ្នារវាងខ្ញុំនឹងនាង ធរី នោះ កើតឡើងពី នាងធរីដែលចេះតែមកម៉ក់រកខ្ញុំតែប៉ុណ្ណោះ ។

ក្រោយមួយនៃសប្តាហ៍ទីពីរដែលខ្ញុំនៅសៀមរាប នៅគេហដ្ឋានរបស់នាង ធរី មានការរៀបពិធីជប់លៀងមួយយ៉ាងគគ្រឹកគគ្រេង ដោយឪពុករបស់នាង ជាអ្នកចាត់ចែង ។ ខ្ញុំក៏ត្រូវបានគេអញ្ជើញឲ្យទៅចូលរួមសប្បាយក្នុងពិធីនេះដែរ ។ យប់នេះដូចជាគ្រោះកាក្រក់បន្តិចសំរាប់រូបខ្ញុំ

ព្រោះខ្ញុំបានត្រូវមិត្តភក្តិបន្ដកស្រាជាច្រើន ៗ មួយកែវហើយមួយកែវទៀតតាមសេចក្តីសុំពីមិត្តភក្តិនេះ បានធ្វើឲ្យខ្ញុំលែងដឹងខ្លួនប្រាណនៅពេលយប់ជ្រៅ . . . .

ខ្ញុំបានដឹងខ្លួនប្រាណឡើងវិញ នៅពេលអរុណរះ . . .

នៅពេលដឹងខ្លួននេះ ខ្ញុំបានឃើញនាង ធរី រួមដំណេកជាមួយខ្ញុំនៅលើផ្ទះនាង ដោយដាក់ក្បាលផ្ទាល់នឹងដើមទ្រូងរបស់ខ្ញុំ ហើយដៃឆ្វេងរបស់នាងឱបខ្ញុំ ៗ ខ្ញុំនឹកឆ្ងល់ក្រៃណាឆ្ងល់ ហេតុអ្វីក៏បានជាខ្ញុំត្រូវមករួមដំណេកជាមួយនាងដូច្នេះ? ខ្ញុំលើកដៃនាង ធរី ដែលឱបខ្ញុំចេញ នាងភ្ញាក់ដឹងខ្លួនហើយសំឡឹងមើលមុខខ្ញុំ ដោយក្រសែភ្នែកដែលមានលេស មានន័យ . . . .

— លោក! (នាង ធរី សួរខ្ញុំមុន) លោកភ្ញាក់ហើយឬ ?

— បាទ! (ខ្ញុំឆ្លើយហើយសួរទៅនាងវិញ) ហេតុ



អីក៏បានជាខ្ញុំត្រូវមកគេងជាមួយអ្នកនាងនៅទីនេះអញ្ចឹង ?

— ពីយប់មិញនេះ លោកស្រវឹងស្រាជាខ្លាំង — លោកប៉ាបានឲ្យគេគ្រាហ៍លោកមកគេងនៅកន្លែងនេះ ហើយបានឲ្យខ្ញុំនៅកំដរលោក . . .

គ្រាន់តែនិយាយផុតពាក្យប៉ុណ្ណោះ នាង ធរី ក៏ក្រោកឡើងហើយចេញទៅក្រៅបន្ទប់ ៗ មួយសន្ទុះក្រោយមក នាងក៏ចូលមកក្នុងបន្ទប់វិញ ដោយមានចានដែកទឹកក្តៅនិងកន្សែងពោះគោ ៗ នាងបានជូតមុខមាត់និងខ្លួនប្រាណឲ្យខ្ញុំ ៗ ខ្ញុំក៏ចេះតែសម្ងំឲ្យនាងជូតទៅ ៗ

ខ្ញុំក្រោកឡើងជក់បារីយ៉ាងឈ្ងុយឆ្ងាញ់ ដូចជាធ្វើឲ្យការសាំញ៉ាំនៅក្នុងខ្លួនប្រាណនឹងចិត្តគំនិត ហើរសាត់បាត់ទៅតាមផ្សែងបារី . . .

ខ្ញុំនឹកដូចជាចង់បន្ទោសខ្លួនឯងថា ពុំគួរជាបណ្ដោយឲ្យមានការធ្វស់ធ្លោយដូច្នេះកើតឡើងសោះ ព្រោះជាការពុំ

សមត្ថភាពដល់ឋានៈនៃនាយទាហានដូចជារូបខ្ញុំ ...... អគ្គសេនាធិការគង់យោធពលខេមរភូមិន្ទ បានចាត់រូបខ្ញុំឲ្យទៅប្រតិបត្តិការនៅសៀមរាប ពុំគួរជាខ្ញុំទៅមានរឿងពុំល្អ ពុំគប្បីយ៉ាងនេះឡើយ ....

នាង ធរី បានចូលមកម្តងទៀត ៗ នាងបានប្រាប់ខ្ញុំថា ឪពុកនាងកំពង់តែអង្គុយចាំខ្ញុំនៅបន្ទប់ទទួលភ្ញៀវ ៗ ខ្ញុំក៏រៀបចំខ្លួនចេញទៅជួបទាំងខ្មាសអៀន ៗ

— ម៉េចលោក ? ( លោកអនុសេនីយទោនោះសួរខ្ញុំ ) លោកបាត់ស្រវឹងហើយឬ ?

— បាទ ! បាត់ហើយ ..(ខ្ញុំឆ្លើយដោយការអៀនខ្មាស)

— ពីយប់មិញនេះ លោកស្រវឹងខ្លាំងណាស់

— បាទ ! ខ្ញុំស្រវឹងពាល់តែលែងដឹងខ្លួន លោកអនុសេនីយទោចាស់ បានសំឡឹងមើលមុខខ្ញុំស្ទើរតែពុំព្រិចភ្នែក ដែលមើលទៅ ហាក់ដូចជាចង់សង្កេតពិនិត្យមើលការពិតអ្វី



ម្យ៉ាងពីរូបខ្ញុំ ៗ ខ្ញុំក៏ដាក់មុខចុះ ព្រោះពុំហ៊ានប៉ះក្រសែភ្នែកឪលោក ហើយបរិយាកាសបានស្ងប់ស្ងៀមទៅមួយសន្ទុះធំ ៗ

— លោក ! (លោកអនុសេនីយទោចាស់បានទម្លាយនូវបរិយាកាសស្ងប់ស្ងៀមនោះឡើង) ឥឡូវលោកគិតយ៉ាងម៉េចចំពោះរឿងពីយប់មិញនេះ ?

— រឿងពីយប់មិញយ៉ាងម៉េចលោក ? (ខ្ញុំសួរទៅវិញ ព្រោះពុំយល់ដល់សំនួរនោះ ៗ

— ឌុ ! លោកនៅតែធ្វើពើដូចជាមិនដឹងទៀតឬ ! ធរី ជាកូនស្រីរបស់ខ្ញុំ លោកបានរួមរ័កជាមួយកូនស្រីរបស់ខ្ញុំ ឥឡូវខ្ញុំចង់ដឹងថា តើលោកគិតយ៉ាងណាក្នុងរឿងនេះ ?

តាមពិត ខ្ញុំឥតបានដឹងអ្វីទាំងអស់ ព្រោះខ្ញុំស្រវឹងស្រា ៗ អ្នកណាគ្រាហ៍ខ្ញុំយកទៅដាក់ឲ្យដេកលើគ្រែនោះ ហើយនាង ធរី ទៅដេកជាមួយខ្ញុំពីពេលថ្មើរណានោះ ខ្ញុំក៏

ឥតបានដឹងទាល់តែសោះ ។ ខ្ញុំជឿជាក់ថា ខ្ញុំឥតបានប្រព្រឹត្តលើសលស់អ្វីលើរូបនាង ធរី ដល់តិចតួចសោះឡើយ កាលបើខ្ញុំស្រវឹងស្រាទាល់តែលែងដឹងខ្លួនដូច្នេះ ។ ប៉ុន្តែខ្ញុំក៏គ្មានហេតុផល អ្វីដែលនឹងត្រូវលើកយកមកធ្វើជាសំអាងដែរ ព្រោះតាមធម្មតាកំឡោះនិងក្រមុំ កាលបើដេករួមគ្រែមួយជាមួយគ្នាយ៉ាងនេះ ក៏ពិបាកនឹងនិយាយឲ្យគេជឿថាខ្លួនជាមនុស្សត្រឹមត្រូវមិនប៉ះពាល់គ្នា ក្រៅពីពួកទេវតាដែលមានភ្នែកទិព្វត្រចៀកទិព្វប៉ុណ្ណោះ ។

— រឿងនេះ! (ខ្ញុំឆ្លើយទាំងប្រថុយ ព្រោះមិនដឹងជាឆ្លើយថាដូចម្តេចក្រៅពីនេះ) ខ្ញុំក៏ពុំដឹងជាគិតយ៉ាងណាដែរ សុំឲ្យលោកមេត្តាជួយគិតខ្ញុំឲ្យបានស្រួលផងចុះ ...

— រឿងនេះ ខ្ញុំក៏មិនថាអីដែរ ព្រោះវាបានជាជ្រុលហួសទៅហើយ ខ្ញុំសុំឲ្យលោកកុំធ្វើឲ្យខ្ញុំខ្មាសគេតែប៉ុណ្ណោះ ... ខ្ញុំសុំបញ្ជាក់ថា យើងជាទាហានទាំងអស់គ្នា កាលបើលោក



មិនទុកមុខទុកមាត់ឲ្យខ្ញុំទេ ខ្ញុំក៏គ្មានអីឆ្លើយទៅលោកវិញ ក្រៅពីគ្រាប់កាំភ្លើងទេ ... ហើយលោកនៅផឹកតែលេងសិនចុះ ខ្ញុំទៅធ្វើការហើយ ... ។

លោកអនុសេនីយទោនេះ ក្រោកដើរចេញទៅក្នុងខណៈដែលនិយាយផុតពាក្យ ដោយមិនទុកពេលឲ្យខ្ញុំនិយាយតទៅទៀត ។ ខ្ញុំចង់ឆ្លើយថា ខ្ញុំក៏ជាទាហានដែរ ហើយការប្រើគ្រាប់រំសេវក៏ចេះប្រើដូចគ្នាដែរ តែខ្ញុំខប់ខាន់ ព្រោះគិតថា ខ្ញុំពុំគួរជាប្រើគ្រាប់រំសេវជាមួយនឹងបងប្អូនរួមលោហិតឡើយ ...

ក្រោយពេលដែលឪពុកនាងចុះចេញផុតបន្ទប់ទៅ នាង ធរី បានចូលមកអង្គុយនិយាយលេងពីនេះពីនោះជាមួយខ្ញុំ ។ ខ្ញុំប្រើវិធីត្រជាក់និយាយលេងជាមួយនាង ហាក់ដូចជាគ្មានរឿងរ៉ាវអ្វីកើតឡើង ។ នៅម៉ោង៩កន្លះ ខ្ញុំក៏បានលានាងត្រឡប់ទៅកន្លែងវិញ ។

ខ្ញុំអង្គុយគិតម្នាក់ឯងនៅក្នុងបន្ទប់ . . . ខ្ញុំគិតពុំយល់ថា ហេតុអ្វីក៏គេគ្រោហ៍ខ្ញុំ ដែលស្រវឹងស្រាលែងដឹងខ្លួនឲ្យទៅដេកជាមួយនាង ជរី ដូច្នេះ ? មានខណៈចិត្តខ្លះ ខ្ញុំចង់គិតថាក្រែងគេត្រូវការអ្វីពីរូបខ្ញុំទេដឹង ? ព្រោះគេឃើញខ្ញុំនៅកំឡោះ មានឋានន្តរស័ក្តិជាអនុសេនីយទោ ហើយនៅធ្វើការក្នុងក្រុមចារកម្មទៀតផង ។ នាង ជរី ជានារីមានការសិក្សាជ្រៅជ្រះ ឪពុកនាងទៀតសោតក៏មានឋានន្តរស័ក្តិជាអនុសេនីយទោដែរ មិនគួរណាជាពុំដឹងការអាក្រក់ល្អយ៉ាងនេះទេ ។ ពិតណាស់គេប្រហែលជាត្រូវការអ្វីម្យ៉ាងពីរូបខ្ញុំហើយមើលទៅ ... បើពុំដូច្នោះទេ គេមុខជាពុំធ្វើយ៉ាងនេះឡើយ . . .

លុះគិតដូច្នេះហើយ ខ្ញុំក៏សំរេចចិត្តថា ពុំត្រូវបោះបង់នាង ជរី ចោល ។ ខ្ញុំត្រូវតែបំពេញបំណងរបស់នាង ជរី ដែលចង់បានរូបខ្ញុំធ្វើជាប្តី និងបំណងរបស់ឪពុកនាង ដែលចង់បានរូបខ្ញុំធ្វើជាកូនប្រសា ក្រែងលោបានដឹង



ការណ៍អាថ៌កំបាំងអ្វីអ្នកខាងនេះ ។ ខ្ញុំជានាយទាហានធ្វើការក្នុងក្រុមចារកម្ម កាលបើបានមកជួបប្រទះនឹងហេតុការណ៍ដូច្នេះហើយ បោះបង់ចោលដោយដកខ្លួនថយនោះ គឺដូចជាឆោតពេក ។ ខ្ញុំគិតថា គួរតែប្រថុយចាំមើលបន្តិចតទៅទៀតសិន ។

ខ្ញុំពុំមែនស្រឡាញ់នាង ជរី ទេ ប៉ុន្តែពាក្យដែលគេតែងនិយាយថា បើមានផ្កានៅជិតដៃបេះថើបលេងទៅ នោះជាពាក្យត្រូវណាស់សំរាប់រូបខ្ញុំ ។ ខ្ញុំបេះបុប្ផានេះថើបលេង ក៏ព្រោះវានៅជិតដៃ ហើយបុប្ផាដ៏ក្រអូបនេះអាចហុចប្រយោជន៍អ្វីម្យ៉ាងឲ្យខ្ញុំក្នុងពេលឆាប់ ៗ នេះផង ។

ចាប់តាំងពីថ្ងៃនោះមក ក្នុងចំណោមមិត្តភក្តិរបស់ខ្ញុំ គេដឹងគ្រប់គ្នាថា ខ្ញុំស្រឡាញ់នាង ជរី យកធ្វើជាប្រពន្ធ ។ ឯរូបខ្ញុំវិញ ក៏ពុំធ្វើអ្វីឲ្យនាងដឹងថាខ្ញុំពុំស្រឡាញ់នាងឡើយ ។

ព្រលប់នៃថ្ងៃមួយ ខ្ញុំត្រូវធ្វើដំណើរត្រឡប់ទៅភ្នំពេញ

តាមទូរលេខបញ្ជាការពិសេស ពីលោកវរសេនីយត្រី ហង្ស-ចំរើន នាយក្រុមចារកម្ម ដែលត្រូវជានាយចៅហ្វាយផ្ទាល់របស់ខ្ញុំ

## វគ្គទី ៩

# បំពេញបេសកកម្មពិសេស

រាត្រីនេះ ជារាត្រីមួយប្រកបដោយមេឃស្រឡះអាកាសស្ងប់ ៗ យើងបានធ្វើដំណើរចេញផុតពីផ្សារកំពង់ក្ដី ហើយ ៗ ភ្នាក់ងារសម្ងាត់លេខ ៨ បានកាន់ចង្កូតរថយន្ត ហើយបញ្ជាឲ្យលូនទៅមុខ ក្រោមស្រមោលនៃរុក្ខជាតិនានា។

ការស្ងាត់ស្ងៀមក្នុងការធ្វើដំណើរនេះ បានធ្វើឲ្យខ្ញុំជញ្ជឹងគិតដល់បេសកកម្មរបស់ខ្ញុំ ... ខ្ញុំជញ្ជឹងគិតដោយការនឿងឆ្ងល់ជាខ្លាំងនូវកិច្ចការដែលខ្ញុំត្រូវធ្វើ ក្នុងគោលបំណងបំភាន់មតិខ្មាំងដែលអាចមានមនុស្សរាប់រយរាប់ពាន់នាក់ ត្រូវជាប់អន្ទាក់នេះ ... ខ្ញុំសំឡឹងមើលរុក្ខជាតិដែលដុះរត់ជួរតាមបណ្ដោយផ្លូវទាំងខាងឆ្វេងនិងទាំងខាងស្ដាំ ក្រោមពន្លឺព្រះច័ន្ទថ្លា ដែលឃើញដូចជាស្រមោលស្មុក ៗ.. ៗ ស្រមោលរុក្ខជាតិទាំងនេះ ហាក់ដូចជាបានខ្សិបដាក់ត្រចៀករបស់ខ្ញុំថា ៖

អាក្បត់ ! ... អាក្បត់ ! ! ! ។

ខ្ញុំបានពោលកន្ទុយភ្នែកមើលនាឡិការបស់ខ្ញុំ ឃើញទ្រនិចខ្លីចង្អុលម៉ោងម្ភៃ ។ ខ្ញុំបានសួរភ្នាក់ងារលេខ ៨ ថា៖

— ជិតដល់ហើយឬនៅ ?

— បាទបាន ! ជិតដល់ហើយ — ពួកវាត្រូវនៅចាំយើងត្រង់កន្លែងមួយជិតព្រំប្រទល់ខេត្តសៀមរាប កំពង់ធំ ដែលមានផ្លូវរទេះកាត់ ជិតភូមិប្រឡាយ ហើយឲ្យសញ្ញាយើង ដោយពន្លឺភ្លើងពិល ...

បន្តិចក្រោយមក យើងក៏បានឃើញសញ្ញាពន្លឺភ្លើងពិលបីដង ។ ភ្នាក់ងារលេខ ៨ ក៏បញ្ឈប់រថយន្តតែជ្រុលហួសទៅមុខប្រហែល ១០ ម៉ែត្រ ។ យើងត្រូវថយរថយន្តមកក្រោយវិញ ហើយមកឈប់ចម្ងាយ ៥ ម៉ែត្រពីកន្លែងភ្លើងសញ្ញា ។ ខ្ញុំសង្កេតឃើញថា ពួកវាបររថយន្តតាម



ផ្លូវរទេះ ដែលចុះពីផ្លូវថ្នល់ទៅប្រហែលជា ៥ ម៉ែត្រដែរ ។ ភ្នាក់ងារលេខ ៨ បាននិយាយនឹងខ្ញុំតិច ៗ ថា៖

ខ្ញុំត្រូវឈប់រថយន្តចម្ងាយ ៥ ម៉ែត្រអញ្ចឹងក្រែងលោមានការមិនស្រួល—សុំលោករង់ចាំខ្ញុំមួយភ្លែត ចាំខ្ញុំទៅមើលសិន បើបានការតាមសន្យាហើយ ចាំខ្ញុំមកនាំលោកទៅ ...

— ហ្នឹងហើយទៅចុះ

— លោក ! (ភ្នាក់ងារលេខ ៨ និយាយបែបចំអកក្រោយពេលដែលគ្រឿងចក្ររថយន្តរលត់) លោកប្រហែលជាពេញចិត្តក្នុងការក្បត់នេះដែរមែនទេលោក ?

— ខ្ញុំពុំសូវពេញចិត្តប៉ុន្មានទេ តែខ្ញុំពេញចិត្តទៅប្រយុទ្ធជាមួយខ្មាំងជាង ។

— លោក ! មុខងារចារបុរសក៏ពុំខុសគ្នាពីមុខងារដទៃដែរ ... មុខងារនេះមានសារៈប្រយោជន៍សំខាន់ណាស់ក្នុងខណៈដែលខ្មាំងនៅពុំទាន់ដឹងខ្លួន តែនៅពេលដែលខ្មាំងរក

ដឹងខ្លួនហើយ ចាប់រូបតារបុរសនោះបាន ក៏គ្មានអ្វីក្រៅពី គ្រាប់កាំភ្លើង ១២ គ្រាប់របស់ខ្មាំងជារង្វាន់ទេលោក ...

ខ្ញុំនៅស្ងៀមពុំឆ្លើយថាអ្វី ព្រោះខ្ញុំគិតថា មុខងារជា តារបុរសពុំមែនជាមុខងារស្រួលឡើយ ហើយខ្ញុំក៏ដូចជាពុំ ទើន(១) ឮនូវពាក្យថាតារបុរសនេះផង ។

ភ្នាក់ងារលេខ ៨ និយាយទៅទៀតថា ៖

— ខ្ញុំដូចជាចង់តែអស់សំណើច កាលបើខ្ញុំនឹកឃើញ ដល់រឿងដែលថា ពុំគួរជាយកប្រាក់សាមសិបម៉ឺនរៀលមក ទិញក្រដាសឥតតម្លៃនេះសោះ ! ...

និយាយចប់ហើយ ភ្នាក់ងារលេខ ៨ ក៏ចុះដើរតម្រង់ ទៅកន្លែងដែលខ្មាំងរង់ចាំ ។ សភាពងងឹតបានបិទបាំង រូបកាយគេឲ្យមើលទៅឃើញតែស្រមោលស្លុង ៗ ។ ខ្ញុំ អុចបារីជក់ហើយដើរក្រេះក្រោះជុំវិញរថយន្ត ។

---

១ – ទើង ជាកិរិយាសព្ទប្រែថាចង់



ប្រមាណជាដប់នាទីបានកន្លងផុតទៅ សេចក្ដីបារម្ភរបស់ ខ្ញុំក៏បានផុសឡើង ។ ខ្ញុំគិតថា ភ្នាក់ងារសម្ងាត់របស់ខ្មាំង ប្រហែលជាបានដឹងនូវឧបាយកលទុច្ចរិតរបស់ខ្ញុំ តែក្នុងពេល ដែលខ្ញុំកំពុងតែបារម្ភនោះ ខ្ញុំក៏ឮសូរស្បែកជើងមនុស្សដើរ ចូលមកជិតខ្ញុំ ។ ខ្ញុំបានពិនិត្យឃើញស្រមោលខ្មៅស្លុង ៗ ពីរបានទិតចូលមកជិតខ្ញុំ ។ បន្តិចមកភ្នាក់ងារលេខ ៨ និង មនុស្សម្នាក់ទៀតបានដើរចូលមកជួបនឹងខ្ញុំ ។ ភ្នាក់ងារលេខ ៨ បានបញ្ចេញនូវកាយវិការគោរពខ្ញុំប្លែកពីធម្មតា ។

— ព្រះតេជ–គុណ ! (ភ្នាក់ងារលេខ ៨ ណែនាំខ្ញុំ ក្រោយដែលបានគោះកែងគោរពខ្ញុំ) ខ្ញុំបាទសុំបង្ហាញមនុស្ស ដែលយើងត្រូវជួបតានៈប្រាស ។

— លោក ! (ខ្ញុំសួរដោយពាក្យដាច់ខាត) លោកមាន ប្រាក់គ្រប់ចំនួនហើយឬ ?

— បាទ ! មានគ្រប់ចំនួនហើយ (តារបុរសរបស់

ខ្លាំងបានឆ្លើយឡើងព្រមទាំងហុចកញ្ចប់ប្រាក់មកឲ្យខ្ញុំ) ។

ខ្ញុំទទួលយកហើយ ក៏ហុចស្រោមសំបុត្រដែលបន្តិចនូវឯកសារពិសេសទៅឲ្យគេវិញ ។ គេញញឹមញញែមដោយការពេញចិត្តជាខ្លាំង ។ គេបានសំដែងនូវអំណរគុណចំពោះខ្ញុំ រួចហើយក៏លាត្រឡប់ទៅវិញដោយមានភ្នាក់ងារលេខ ៨ ជាអ្នកជូនដំណើរទៅដល់កន្លែងដើម ។

មួយសន្ទុះក្រោយមក ភ្នាក់ងារលេខ ៨ ក៏ត្រឡប់មកវិញ ហើយយើងក៏នាំគ្នាបន្តដំណើរទៅភ្នំពេញ យ៉ាងរួសរាន់ ។ នៅតាមផ្លូវភ្នាក់ងារលេខ ៨ បានរាយការណ៍ប្រាប់ខ្ញុំពីរឿងនេះ ។ គេនិយាយរឿងនេះ ដូចជារឿងត្លុកកំប្លែងគួរឲ្យចង់សើចថា:

– លោក ! ខ្ញុំនិយាយប្រាប់ពួកវាថា លោកបានក្លាយក្នុងការលេងល្បែងស៊ីសង ដោយបានយកប្រាក់រដ្ឋការទៅលេងចាញ់អស់ជាច្រើន ហើយក្នុងការរកប្រាក់បង្គ្រប់វិញ



នេះ ជារឿងអាយុជីវិតរបស់លោកដែលត្រូវតែគេឲ្យទាន់នៅថ្ងៃខានស្អែកនេះ . .

តពីនោះមក ខ្ញុំក៏បានដេកលក់នៅលើរថយន្ត ។ លុះភ្ញាក់ឡើង ក៏ស្រាប់តែឃើញរថយន្តឈប់នៅលើសាឡាងព្រែកក្តាមដែលឆ្លងមកជិតដល់ត្រើយខាងលិចទៅហើយ ។

ខ្ញុំបានស៊ុបបារីដេក ហើយបណ្តោយឲ្យភ្នាក់ងារលេខ ៨ បើកបររថយន្តដោយស្ងប់ស្ងៀម . . .

រថយន្តបានលួនចូលដល់ទីក្រុងភ្នំពេញនៅម៉ោង ២៤ អាធ្រាត្រ ។ ខ្ញុំបេះតែមានសតិអារម្មណ៍ស្រាប់ស្រស់ ហើយនឹកការមួយម៉ឺនដំពូក ។ ខ្ញុំក៏បាននិយាយទៅកាន់ភ្នាក់ងារលេខ ៨ ថា ៖

– សុំនាំយកខ្ញុំទៅដាក់ឯផ្ទះចុះ . . .

– បាទ ! លោកវរសេនីយត្រីបានផ្តាំថា បើបានសំរេចការហើយ នៅពេលដែលត្រឡប់មកដល់រាជធានីវិញ

លោកឲ្យខ្ញុំនាំលោកទៅកំសាន្ត ក្នុងវត្តសាលណាមួយសិន ដើម្បីជាការផ្លង់នូវជោគជ័យរបស់យើង ... ហេតុនេះយើងគួរទៅរកដាក់ម្នាក់មួយកែវសិន ...

យោបល់របស់ភ្នាក់ងារលេខ ១៨ និងបណ្ដាំរបស់លោកវរសេនីយត្រីដូចជាគួរស្ដាប់ណាស់ ។ ខ្ញុំក៏យល់ព្រមតាម ។ ភ្នាក់ងារលេខ ១៨ បាននាំខ្ញុំចូលទៅក្នុងវត្តសាល (ម៉ាឡៃយ៉ា) ជិតនៅជិតពលរង់បរសេះ ។ យើងបានអង្គុយផឹកទឹកជជែកគ្នាស្រើៗ ។ នៅទីនោះ ភ្នាក់ងារលេខ ១៨ បានរៀបប្រាប់ខ្ញុំថា ហៅវត្តសាលនេះឈ្មោះយ៉ូយ៉ាំងញ៉ុំ ... ជាត្រូវក្រុមប្រឆាំងនឹងចារកម្មរបស់យើងសង្ស័យថា ជាចារបុរសរបស់ពួកផាប-ឈ្លួ .. ការដែលយើងចូលមកក្នុងនេះ ជា



មុខជានាំពត៌មាននេះទៅប្រាប់ទៅហ្វាយក់ ... ប្រសិនបើរឿងនេះពិតដូច្នោះមែន ក៏ជាការប្រសើរណាស់ដែរព្រោះជាអាចនាំនូវភាពសក្តិសិទ្ធិនៃរឿងក្បត់ជាតិរបស់យើង ឲ្យរឹងរិតតែពិតប្រាកដឡើងទៀត ។

## វគ្គទី ១០

# ការកាត់ទោសប្រហារជីវិត

យប់នេះ ខ្ញុំដេកលង់លក់ឥតដឹងខ្លួនប្រហែលព្រោះខ្ញុំអត់ងងុយតាំងតែយប់ជ្រៅ ។ ខ្ញុំភ្ញាក់ដឹងខ្លួនឡើងនៅពេលដែលសូរគោះទ្វារពីខាងក្រៅ ។ ខ្ញុំចោលភ្នែកក្រឡេកមើលនាឡិកា ឃើញទ្រនិចចង្អុលលេខ ៦ ។ ខ្ញុំក្រោកពីដំណេកទៅបើកទ្វារទាំងងងុយដោយមានការស្ញប់ពីរចិត្ត ។

ខណៈដែលខ្ញុំបើកទ្វារភ្លាម ខ្ញុំបានឃើញកងរាជអាវុធហត្ថប្រហែលជាដប់នាក់ ឈរតម្រៀបគ្នានៅខាងក្រៅដោយមានអនុសេនីយត្រីម្នាក់ជាអ្នកនាំឈរមុខគេ ។ ខ្ញុំដូចជាភ្ញាក់ផ្អើលក្តុក ព្រោះពុំដឹងជាមានការអ្វី ? ក្នុងពេលដែលខ្ញុំឈរស្រឡាំងកាំងនៅមាត់ទ្វារ អនុសេនីយត្រីនេះក៏គំនាប់ខ្ញុំហើយនិយាយឡើងថា ៖



— លោក ! អគ្គសេនាធិការបានបញ្ជាពួកខ្ញុំឲ្យមកអញ្ជើញលោកទៅ . . .

គ្រាន់តែឮពាក្យនេះខ្ញុំក៏ផ្លាស់ទឹកមុខ ព្រោះគិតថា ការដែលគេប្រើកំឡាំងយ៉ាងនេះ ក៏សម្រាប់តែមនុស្សដែលមានទោស ។ ខ្ញុំទប់ស្មារតី ហើយសួរទៅវិញថា ៖

— ចុះបើគ្រាន់តែមកហៅខ្ញុំទេ ហេតុអីក៏បាំនាំទាហានមកច្រើនម្ល៉េះ ?

— បាទ ! ខ្ញុំក៏ពុំដឹងដែរ តែខ្ញុំធ្វើតាមបញ្ជាអគ្គសេនាធិការ - - -

— គេបញ្ជាថាម៉េចខ្លះ ?

— បាទ ! ឲ្យមកអញ្ជើញលោកទៅឲ្យខាងតែបាន តែបើលោករឹងរូស ត្រូវប្រើកំឡាំងអាវុធ,

— បើអញ្ចឹងបានសេចក្តីថា រូបខ្ញុំជាមនុស្សមានទោស?

— ការនេះ ខ្ញុំក៏ពុំដឹងដែរ ស្រេចតែលោកគិតចុះ ។

ក្រោយពេលបានលប់មុខនឹងស្លៀកពាក់ស្រួលបួលហើយ ខ្ញុំក៏បានធ្វើដំណើរទៅទីបញ្ជាការឧត្តមសេនាធិការ ជាមួយក្រុមរាជអាវុធហត្ថ ដោយរថយន្តដែលចតចាំនៅខាងមុខផ្ទះ ។

ពួកនេះបាននាំខ្ញុំ ចូលទៅជួបនឹងលោកវរសេនីយត្រីមាស-ស្អាត នាយក្រុមប្រឆាំងនឹងចារកម្ម ។ ខ្ញុំត្រូវដើរឆ្លងកាត់ពួករាជអាវុធហត្ថ ដែលនៅឈរយាមច្រើនសន្ធឹក ។ ខ្ញុំបានដើរចូលទៅគំនាប់លោកវរសេនីយត្រី ដែលកំពុងតែអង្គុយនៅក្នុងការិយាល័យតាំងព្រឹកព្រហាម ។

— អើ! ( លោកវរសេនីយត្រីនិយាយហើយសំឡឹងមើលខ្ញុំដោយក្រសែភ្នែកដ៏មុត ) ចូលមកលោកស័ក្តិតី ...

ខ្ញុំសំឡឹងមើលមុខលោកវរសេនីយត្រីពុំដាក់ភ្នែក ។ ខ្ញុំធ្លាប់ស្គាល់នាយទាហានជាន់ខ្ពស់រូបនេះតែក្នុងកិត្តិសព្ទដ៏ល្បីល្បាញតែប៉ុណ្ណោះ ។ ខ្ញុំបានសង្កេតឃើញថា ទឹកមុខ



នឹងអាកប្បកិរិយា របស់លោក មានសភាពសមនឹងកិត្តិយសកេត្តិ៍ឈ្មោះដ៏ល្បីល្បាញរបស់លោកមែន ។ លោកជាអ្នកចូលចិត្តកីឡា ។ រូបកាយរបស់លោកស្អាតស្អំ ។ ទឹកមុខរបស់លោកបានបង្ហាញនូវសភាពម៉ឺងម៉ាត់ ។ ក្រសែភ្នែករបស់លោក ដែលឆ្លុះចម្ងាយចេញពីកែវកញ្ចក់វ៉ែនតាស បានបញ្ចេញឲ្យឃើញលក្ខណៈរហ័សរហួនឆ្លៀវឆ្លាត នឹងប៉ិនប្រសប់ក្នុងការសង្កេត ។ លោកវរសេនីយត្រី មាស-ស្អាត មិនមែនមានកិត្តិសព្ទល្បីល្បាញក្នុងការប៉ិនប្រសប់ តែក្នុងមុខតំណែងរបស់លោកប៉ុណ្ណោះទេ លោកមានកិត្តិសព្ទល្បីល្បាញខាងការទាក់ទងនឹងស្រីទៀតផង ។ ថ្វីបើលោកមានវ័យចាស់បន្តិច ។ ប៉ុន្តែជួនកាលលោកអាចដណ្តើមយកជ័យជំនះ ក្នុងរឿងស្នេហាពីគូប្រណាំងប្រជែងកំលោះៗ ខ្លះបានក៏មាន ។ ថ្វីដៃប៉ិនប្រសប់ក្នុងរឿងស្នេហារបស់លោកវរសេនីយត្រីនេះ បានធ្វើឲ្យអ្នកដែលធ្លាប់ស្គាល់លោកដាក់

ឈ្មោះក្រៅសម្រាប់ហៅលេងថា " ស្អាត ដាច់ចិត្ត " ។

— លោកសក្តិតិ ! (លោកវរសេនីយត្រីចាប់និយាយឡើង) ខ្ញុំមានសេចក្តីស្តាយណាស់ក្នុងការដែលខ្ញុំបានដឹងថា លោកក្បត់ជាតិ — មនុស្សដូចលោកពុំគួរជាប្រព្រឹត្តនូវអំពើថោកទាបយ៉ាងនេះសោះ — ទោសធម្មតាសំរាប់មនុស្សក្បត់ជាតិគឺប្រហារជីវិត — ខ្ញុំត្រូវទទួលភារៈ បញ្ជូនខ្លួនលោកឲ្យតុលាការសឹកជុំនុំជំរះ កាត់ទោស — ខ្ញុំជឿជាក់ថាតុលាការសឹកមុខជាកាត់ទោសប្រហារជីវិតពុំខាន ...

ខ្ញុំក្រាក់ខ្លួនព្រឺតដូចគេគ្រោក ។ ខ្ញុំថ្លស់ទឹកមុខ ត្រជាក់ខ្លួនស្រិប ហើយព្រឺព្រួចសព្វសព៌ាង្គកាយ ។

លោកវរសេនីយត្រីនិយាយតទៅទៀតថា !

— រឿងនេះជារឿងពិត ! លោកដឹងខ្លួន ។ ឯងស្រាប់ហើយ ...

— បាទ ! (ខ្ញុំដំតាស់ឡើង) រឿងនេះខ្ញុំធ្វើតាមបញ្ជា ...



— ឈប់ ! ឈប់និយាយលោកសក្តិតិ ! (លោកវរសេនីយត្រីទះតុហើយស្រែកគំហក) លោកដឹងខ្លួនស្រាប់ហើយទេតើ — នៅក្នុងអគ្គសេនាធិការរបស់យើង គេបាត់សំណុំរឿងផែនការ សម្ងាត់សំរាប់វាយលុកចូលទៅចាប់ខ្មាំង — ផែនការនេះជារបស់មានតម្លៃថ្លៃណាស់ ព្រោះជាផែនការដែលគេរៀបចំឡើង សំរាប់ការពារអាយុជីវិតនៃប្រទេសជាតិ — ឥឡូវនេះ ការស៊ើបអង្កេតបានឲ្យដឹងថាលោកជាអ្នកលួចយកផែនការនេះទៅលក់ឲ្យបច្ចាមិត្ត ដោយមានភស្តុតាងគ្រប់គ្រាន់ — លោកដឹងហើយថាទោសរបស់អ្នកក្បត់ជាតិនោះគឺគ្រាប់កាំភ្លើង ១២ គ្រាប់ — បើខ្ញុំពុំរវល់ធ្វើទោសដល់លោកដែលជាមនុស្សក្បត់ជាតិទេនោះ គឺដូចជាខ្ញុំចូលដៃចូលជើងជាមួយលោក ...

ខ្ញុំស្រឡាំងកាំងដូចរូបតុក្កតា ឬ ដូចមនុស្សដែលគ្មានវិញ្ញាណ ។ ក្រសែភ្នែករបស់ខ្ញុំបែកគំពិលអំពែកព្រោង ។

ដំណក់ញើសដ៏ធំ ៗ បានជ្រាបចេញពីថ្ងាសដោយពុំដឹងខ្លួន ។ វិញ្ញាណរបស់ខ្ញុំ ដូចជាហោះហើរចេញពីរាងកាយបាត់ ។ ខ្ញុំលែងដឹងឃើញអ្វីទាំងអស់ . . . លោកវរសេនីយត្រីសំឡឹងមើលមុខខ្ញុំដោយក្រសែភ្នែកដ៏មុត ៗ លោកប្រហែលជាសង្កេតឃើញថា ខ្ញុំមានសេចក្តីភិតភ័យខ្លាំង ។ ខណៈនោះ លោកក៏បញ្ជាឲ្យអនុសេនីយត្រី ក្រុមពលគារុធហត្ថចេញទៅក្រៅវិញ ហើយលោកក៏និយាយនឹងខ្ញុំ ដោយសម្លេងធូរជាប្រក្រតីថា :

– លោកស័ក្តិពីរ សុំលោកកុំភ័យខ្លាំងពេក ចាំខ្ញុំនិយាយប្រាប់លោក ឲ្យបានដឹងកិច្ចកល់ក្នុងរឿងនេះ . . . លោក ! ការក្បត់របស់លោកជាការមានប្រយោជន៍ធំណាស់ ព្រោះអាចធ្វើឲ្យយើងមានជោគជ័យ . . . ហេតុនេះការក្បត់របស់លោកមានន័យថា ជាពលិកម្មដ៏ខ្ពង់ខ្ពស់ដែលអ្នកដទៃពុំអាចធ្វើបានក្នុងការបំរើប្រទេសជាតិ . . . ខ្ញុំសុំបញ្ជាក់ប្រាប់



លោកថា ការប្រហារជីវិតលើរូបលោកនោះ គឺគ្រាន់តែជាការដែលត្រូវធ្វើលើភាពខាងក្រៅតែប៉ុណ្ណោះ សុំលោកកុំយល់ច្រឡំឲ្យសោះ . . .

– ព្រះតេជ-គុណ ! ភាពខាងក្រៅយ៉ាងម៉េចបានប្រោស ?

– លោកស័ក្តិពីរ ខ្ញុំនិយាយប៉ុណ្ណេះគួរលោកយល់ហើយ-លោកពុំបាច់សួរខ្ញុំឲ្យវែងឆ្ងាយទៀតទេ-លោកមើល-មើល ! នេះគឺជាសំណុំរឿងដែលខ្ញុំបានធ្វើចប់ស្រេចហើយ ដើម្បីដាក់ប្រកាន់ទោសលើរូបលោកពីការក្បត់ជាតិ . ឥឡូវនេះ ខ្ញុំត្រូវបញ្ជូនរូបលោកទៅឃុំឃាំងទុក រង់ចាំពេលជំនុំជំរះកាត់ទោសលោកតែប៉ុណ្ណោះ ។

– បើអញ្ជើញ ព្រះតេជ គុណមេត្តាអនុញ្ញាតឲ្យខ្ញុំបានជួបជំរាបលាដល់ឪពុកម្តាយខ្ញុំបានសិន បានប្រោស ដើម្បីកុំឲ្យលោកព្រួយចិត្ត . . .

– ពុំបានទេលោកស័ក្តិតារ លោកធ្វើអញ្ចឹងពុំបានជាដាច់ខាត – លោកត្រូវដឹងថា យើងត្រូវធ្វើការនេះដោយស្ងាត់កំបាំងជាទីបំផុត កុំឲ្យរឿងនេះបែកការ – យើងសង្ឃឹមថា ផែនការអាថ៌កំបាំងនេះ អាចធ្វើឲ្យយើងមានជោគជ័យ – បើរឿងនេះបែកការ ប្រទេសជាតិទាំងមូលនឹងត្រូវទទួលនូវសេចក្តីអន្តរាយណាលោក . .

ការបង្អៀតបង្អល់ចិត្តយ៉ាងខ្លាំងបានកើតឡើងដល់រូបខ្ញុំៗ ខ្ញុំមានទឹកចិត្តពោរពេញដោយការអួរហ្មង ព្រោះខ្ញុំនឹកដល់វាសនាអាក្រក់របស់ខ្ញុំ ដែលកើតមកខុសគេ ៗ ខ្ញុំនឹកគួស វាសដល់ភាពទុក្ខព្រួយនៃឪពុកម្តាយបងប្អូនរបស់ខ្ញុំ និងពាក្យជេរប្រទេចផ្តាសារបស់មហាជនចំពោះរូបខ្ញុំ គ្រួសារខ្ញុំ ព្រោះជាអំពើដែលគេស្អប់ខ្ពើម ៗ

បួនថ្ងៃក្រោយមក សារពត៌មានទាំងអស់នៅទីក្រុងភ្នំពេញ បានចុះផ្សាយនូវដំណឹងមួយក្រោមចំណងជើងថា :



« ការប្រហារជីវិតជនក្បត់ជាតិ »

អនុសេនីយទោម្នាក់ នៃ កងយោធពលខេមរភូមិន្ទ (គេដាក់ឈ្មោះខ្ញុំ) ត្រូវគេចាប់បានក្នុងរឿងក្បត់ជាតិ ហើយឥឡូវត្រូវតុលាការសឹកកាត់ទោសប្រហារជីវិត . . .

ការប្រហារជីវិតជនក្បត់ជាតិនេះ នឹងត្រូវធ្វើនៅពេលព្រឹកនៃថ្ងៃទី ២ កុម្ភៈ ស្អែកនេះនៅទួលគី . . .

ដំណឹងនេះ បានធ្វើឲ្យមហាជនភ្ញាក់ផ្អើលជាខ្លាំង . . .

នៅពេលម៉ោង ៨ ព្រឹកនៃថ្ងៃទី ២ កុម្ភៈ . . .

អនុសេនីយទោម្នាក់នៅក្នុងក្រុមប្រឆាំងនឹងចារកម្ម បាននាំពលបាលឯកម្នាក់ និង ក្រុមនាយទាហានប្រហារមួយក្រុម មកយកខ្ញុំចេញពីបន្ទប់ឃុំឃាំងបណ្តើរឆ្ពោះទៅកាន់កន្លែងប្រហារដោយរថយន្ត ៗ ខ្ញុំត្រូវគេដាក់ខ្នោះដៃជាប់ ៗ នៅទីនោះគេបានជីករណ្តៅមួយសំរាប់កប់ខ្មោចខ្ញុំ ៗ មិនឆ្ងាយពីរណ្តៅនោះប៉ុន្មាន គេដាំបង្គោលមួយមានទំហំធំល្មម ហើយ

មានចំងាយប្រហែលជាពីរម៉ែត្រ ។ បង្គោលនេះហើយដែលគេត្រូវយកខ្ញុំទៅចងភ្ជាប់ហើយប្រហារជីវិត ?

នៅក្រោមពន្លឺព្រលឹមៗនៃអរុណដែលរះរៀបផុតជើងមេឃខាងកើត អនុសេនីយទោចម-ចៅ ជាសហការីរបស់លោកវរសេនីយត្រី មាស-ស្អាត បានបញ្ជាឲ្យខ្ញុំលុតជង្គង់ប្រឈមនឹងបង្គោល ហើយក្រោបមុខទៅនឹងបង្គោលនោះ ។ នៅពីខាងក្រោយខ្ញុំប្រហែលជា ១២ ម៉ែត្រ ពលទាហានមួយក្រុមចំនួន ១២ នាក់ បានឈរកៀកគ្នាជាជួរបែរមុខមករកខ្ញុំ ក្រោមកិច្ចបញ្ជាការរបស់ពលបាលឯកម្នាក់ ។

លុះបានរៀបចំស្រេចហើយ អនុសេនីយទោចម-ចៅ បានលើកដៃស្តាំឡើងជាសញ្ញា ។ ពលទាហានទាំងអស់បានលើកកាំភ្លើងតម្រង់មករកខ្ញុំ ។ ក្នុងខណៈដែលអនុសេនីយទោ ចម-ចៅ ទម្លាក់ដៃចុះវិញ ពលបាលឯកនោះក៏ស្រែកឡើងយ៉ាងខ្លាំងថា :



— បាញ់ !

សូរគ្រាប់កាំភ្លើង ១១ គ្រាប់ ក៏បានលាន់ឮឡើងព្រមគ្នា ។ ខ្ញុំបានសំរុតខ្លួនចុះហើយផ្កាប់មុខទៅលើស្មៅ ។ អនុសេនីយទោ ចម-ចៅ បានដកកាំភ្លើងខ្លីចេញពីបង្កេះ ហើយយកមកផ្ទប់បាញ់ត្រង់ក្បាលរបស់ខ្ញុំជាការបង្ហើយ រួចហើយ គេក៏បញ្ជាទៅពលបាលឯកថា ឲ្យនាំពលទាហានត្រឡប់ទៅបន្ទាយវិញចុះ ឯរូបគេ ត្រូវបានទទួលបង្គាប់ឲ្យនៅចាំប្រគល់សពទៅឲ្យក្រុមញាតិរបស់ខ្ញុំ ដែលនឹងត្រូវមកទទួលយកក្នុងពេលឥឡូវនេះ ។

នៅពេលដែលក្រុមទាហានប្រហារ បានត្រឡប់ទៅបន្ទាយវិញអស់ហើយ លោកអនុសេនីយទោ ចម-ចៅ បានយកជើងមកផ្តិតគូថរបស់ខ្ញុំ ហើយគេនិយាយតិចៗថា :

— រួចហើយសំឡាញ់ ! រឿងកំប្លែងរបស់សំឡាញ់ឯង ត្រូវចប់សព្វគ្រប់អស់ហើយ . . .

ខ្ញុំងើបមុខឡើងទាំងប្រឡាក់ស្រមក ៗ អនុសេនីយ ទោ ជម-ចៅ បានស្រាយចំណងដៃចេញ ហើយនិយាយ នឹងខ្ញុំទៀតថា :

— ទៅសំឡាញ់ ! ឡានខ្ញុំចតចាំសំឡាញ់ឯងនៅខាង នោះ ខ្ញុំប្រាប់សំឡាញ់ឯងពុំទាន់បានថា ខ្ញុំត្រូវនាំសំឡាញ់ ឯងទៅណាទេ ៗ

យើងនាំគ្នាដើរតម្រង់ទៅជិះរថយន្តនោះ ៗ អនុសេនីយទោ ជម-ចៅ ជាអ្នកកាន់ចង្កូតហើយបើកបរចេញពីទីនោះទៅ ៗ

ក្នុងពេលដែលរថយន្តកំពុងតែល្បួនលឿនស្ទៅទៅនោះ ខ្ញុំបានសាកសួរចង់ដឹងដល់រឿងប្រហារជីវិតរបស់ខ្ញុំ ៗ គេ បានថ្លែងប្រាប់ខ្ញុំថា :

— សំឡាញ់ ! សំឡាញ់ឯងឆ្ងល់ទេអី សព្វបើរឿង កាំភ្លើងអញ្ចឹង . . . រូបខ្ញុំហ្នឹងឯង ដែលជាអ្នករៀបចំកាំភ្លើង ទាំង ១៦ ដើម ព្រឹកមិញខ្ញុំបានប្រែកគ្រាប់ក្លែងក្លាយ ក្នុង



កាំភ្លើងទាំងនោះ រួចបានយកទៅឲ្យពលបាលឯកឲ្យចែកដល់ ពួកទាហានទាំងនេះ ពួកទាហានទាំងនោះ ក៏ពុំបានដឹងថា សំឡាញ់ឯងពុំទាន់ស្លាប់ដែរ . . . (អនុសេនីយទោសើច ក្អាកក្អាយរួចនិយាយតទៅទៀត) គ្រាន់តែ ១២ គ្រាប់ចូល ទៅក្នុងខ្លួនសំឡាញ់ឯង សំឡាញ់ឯងប្រហែលជាបានទទួល រង្វាន់មិនតិចទេមើលទៅ . . .

— គ្មានបានទទួលរង្វាន់អ្វីទេ ! . . . ខ្ញុំឆ្លើយឡើង ព្រោះខ្ញុំគិតថា ស្នូរគ្រាប់កាំភ្លើង ១២ គ្រាប់នេះបានចាក់ទម្លុះ នូវបេះដូងឪពុកម្តាយនិងបងប្អូនរបស់ខ្ញុំ ព្រមទាំងបានបំផ្លាញ នូវកិត្តិយសរបស់ខ្ញុំអស់មួយជីវិតទៀតផង . . .

ដោយសារហេតុអ្វីក៏មិនដឹង នៅពេលនោះ ខ្ញុំចេះតែនឹក ស្រម៉ៃដល់នាង យូរ៉េត ទៀត យូរ៉េត ដែលខ្ញុំបានទំលាក់ ព្រាប់ភ្លេចនាងពេលច្រើនសប្តាហ៍ណាស់មកហើយ . . . ខ្ញុំ នឹកថា នាង យូរ៉េត នឹងមានទុក្ខព្រួយយ៉ាងណា ទៅ

ពេលដែលនាងបានទទួលនូវផលនៃអកុសលរបស់ខ្ញុំនេះ ។

ខ្ញុំអង្គុយស្ងៀម ពោលក្លែកសំឡឹងមើលទៅខាងមុខ ដោយទឹកមុខសៅហ្មង ។ អារម្មណ៍របស់ខ្ញុំហាក់ដូចអណ្តែតត្រសែតឆ្ពោះទៅរកនាង យូរ៉ែត ...

— សំឡាញ់ ! សំឡាញ់ឯងកុំឆ្ងល់អ្វីអ្វី (អនុសេនីយ៍ទោ ចម-ចៅ និយាយនឹងខ្ញុំ ក្នុងខណៈដែលខ្ញុំអង្គុយនៅស្ងៀមនោះ) ខ្ញុំបានទទួលបញ្ជាពីលោកសក្តិ ៤ មាស-ស្អាតថា ឲ្យខ្ញុំនាំសំឡាញ់ឯងទៅផ្ទះលោក ព្រោះលោករង់ចាំយើងនៅទីនោះ ...

ខ្ញុំងក់ក្បាលទទួលដឹងដោយពុំបញ្ចេញស្តីថាអ្វី !

លុះបានទៅដល់គេហដ្ឋានរបស់លោកវរសេនីយ៍ត្រី មាស-ស្អាត ហើយ អនុសេនីយ៍ទោ ចម-ចៅ បាននាំខ្ញុំចូលទៅក្នុងបន្ទប់ដ៏ស្ងាត់មួយនៅជាន់ខាងលើ ។ បន្ទប់នេះពុំមែនជាបន្ទប់ទទួលភ្ញៀវទេ គឺជាបន្ទប់ដេក ។ ខ្ញុំនឹក



ឆ្ងល់ជាខ្លាំងថា ហេតុអ្វីក៏បានជាគេនាំខ្ញុំចូលមកក្នុងបន្ទប់នេះ? តែខ្ញុំពុំសួរថាអ្វី ដោយទុកចាំមើលតតទៅទៀត ។ គេបានប្រាប់ខ្ញុំថា ឲ្យខ្ញុំអង្គុយចាំគេនៅក្នុងបន្ទប់នោះ រួចគេនឹងចេញទៅក្រៅបន្តិច ។

មួយសន្ទុះក្រោយមក ក្នុងខណៈដែលខ្ញុំអង្គុយឆ្ងល់តែម្នាក់ឯងនោះ លោកវរសេនីយ៍ត្រី មាស-ស្អាត ក៏ដើរចូលមករកខ្ញុំ ។ លោកបាននិយាយយ៉ាងខ្លីហើយដាច់ខាតថា ឲ្យខ្ញុំដេកនៅក្នុងបន្ទប់ដ៏ស្ងាត់នេះ កុំឲ្យអ្នកណាឃើញឲ្យសោះ ដោយលោកបានតាំងឲ្យលោកអនុសេនីយ៍ទោ ចម-ចៅ ជាអ្នកចាត់ចែងរៀបចំឲ្យបានស្រួលអស់ហើយ ។ ជាអ្នកត្រូវទទួលខុសត្រូវក្នុងរឿងនេះទៀតផង ...

ចាប់តាំងពីពេលនោះមក ខ្ញុំក៏ត្រូវលាក់ខ្លួនពួនអាត្មា នៅក្នុងបន្ទប់ដ៏តូច លើគេហដ្ឋានរបស់លោកវរសេនីយ៍ត្រី មាស-ស្អាត យ៉ាងស្ងាត់ស្ងៀម ...

## វគ្គ ទី ១១

# ចោរកម្ម

ប្រាំមួយថ្ងៃនៅក្នុងខែធ្នូដ៏ស្ងាត់ លើគេហដ្ឋានរបស់លោកវរសេនីយត្រី មាស-ស្អាត ដែលខ្ញុំត្រូវលាក់ខ្លួនក្នុងគ្រានោះ ជាពេលវេលាដ៏យូរ យូរដូចជាពេលប្រាំមួយឆ្នាំសំរាប់រូបខ្ញុំដែលនៅទំនេរគ្មានការអ្វី ។

ប៉ុន្តែនៅពេលល្ងាចនេះ សភាពគគ្រឹកគគ្រេងបានកើតឡើងនៅគេហដ្ឋាននេះ ។ ខ្ញុំបានដឹងដោយសារការលបស្តាប់អនុសេនីយទោ ចម-ចៅ ថាលោកវរសេនីយត្រី មាស-ស្អាត រៀបចំបាត់ពិធីជប់លៀង ដើម្បីជាការជូននូវដំណឹង ក្នុងការដែលលោកត្រូវបានឡើងឋានន្តរសក្តិពិសេសជាវរសេនីយទោ ។ ខ្ញុំក៏បានលបសំដែងនូវសេចក្តីត្រេកអរចំពោះលោកវរសេនីយទោថ្មីនេះដែរ ។



វេលាម៉ោងទី ១៩ ខ្ញុំបានលបមើលឃើញភ្ញៀវទាំងឡាយជាច្រើនបានមកជួបជុំ ។ ខ្ញុំបានឃើញ យ៉ូ-យ៉ាំងញ៉ ម្ចាស់ភត្តាគារ «ម៉ៅខ្សែហ៊ា» មកដើរកាយខ្ញុំជាមួយនឹងគេដែរ ។ ខ្ញុំនឹកឆ្ងល់ជាខ្លាំងថា យ៉ូ-យ៉ាំងញ៉ ជាបុរសសំខាន់ក៏ដែរ បានជាលោក មាស-ស្អាត អញ្ជើញមក ។ តែមួយសន្ទុះក្រោយមក ខ្ញុំបានយល់ច្បាស់ ដោយការសង្កេតឃើញ ក៏ជាអ្នកចាត់ចែងបញ្ជាពួកអ្នកបំរើឲ្យយកម្ហូបអាហារនិងភេសជ្ជៈ ។ ពិតណាស់ (ខ្ញុំគិត) យ៉ូ-យ៉ាំងញ៉នេះ ជាអ្នកទទួលម៉ៅម្ហូបអាហារនិងភេសជ្ជៈក្នុងពិធីជប់លៀងនេះ ។ ខ្ញុំចេះតែលបមើលតទៅទៀត ខ្ញុំភ្ញាក់ព្រើតក្នុងខណៈដែលខ្ញុំបានឃើញនូវសុភាពស្ត្រីម្នាក់ ។ ខ្ញុំញីភ្នែកហើយខំពិនិត្យមើលម្តងទៀត ព្រោះដូចជាពុំទុកចិត្តភ្នែកខ្លួនឯង ។ ពិតណាស់ហើយ គឺពិតជានាង ឆវី នាងឆវី ដែលធ្លាប់រួមរ័កជាមួយខ្ញុំ ។ ប្រសិនបើការ

ស្ថានរបស់ខ្ញុំពុំខុសទេនោះ ខ្ញុំយល់ថាលោកមាស-ស្អាត និងនាងជរី ជាមនុស្សស្រឡាញ់គ្នា ព្រោះខ្ញុំសង្កេតឃើញអាកប្បកិរិយារបស់នាងជរីពេលនោះ ដូចជាតាំងខ្លួនជាម្ចាស់នៃផ្ទះនេះ ។ ខ្ញុំលបមើលដោយការសោប់សល់ក្នុងចិត្ត ព្រោះចង់ដឹងការតទៅទៀតថា តើអ្នកទាំងពីរនាក់ គឺលោកមាស-ស្អាត និងនាងជរី បានគ្នាជាប្តីប្រពន្ធ ឬគ្រាន់តែលបស្រឡាញ់គ្នាទេ ?

នៅវេលាម៉ោង ២១ ភ្ញៀវទាំងឡាយបានលាត្រឡប់ទៅវិញអស់ នៅសល់តែលោកវរសេនីយត្រី ហាង្ស-ចំរើន ម្នាក់ ដែលត្រូវជាមិត្តភក្តិជិតស្និទ្ធរបស់លោកវរសេនីយទោ មាស-ស្អាត និងនាងជរី ។ ខ្ញុំបានសង្កេតឃើញលោកទាំងពីរសប្បាយរីករាយជាខ្លាំង ដោយបាននាងជរីជាអ្នកចាក់ស្រាថែម ។ លោកដូចជាស្រវឹងជ្រុលបន្តិចទៅហើយ ព្រោះត្រូវនាងជរីថែមស្រាញឹកពេក ។



ខ្ញុំភ្ញាក់ផ្អើលៗ ក្នុងខណៈដែលខ្ញុំបានឮលោកវរសេនីយទោ មាស-ស្អាត និយាយទៅកាន់នាងជរីថា ចាក់ស្រាឲ្យបងអូនសំឡាញ់ ! ហើយឃើញលោកឱបថើបនាងបន្តលោកវរសេនីយត្រី ហាង្ស-ចំរើន ក្រោយពេលដែលបានចាក់ស្រាជូនលោករួចហើយ ។

ពិតណាស់ក្នុងលោកនេះ គ្មានបុរសណាមួយអាចឈរមើលសភាពនារីដែលខ្លួនធ្លាប់បានរួមរ័កពីមុនមក ហើយឥឡូវនាងទៅរួមរ័កជាមួយនឹងបុរសដទៃទៀត ក្នុងទីចំពោះមុខដូច្នេះបានឡើយ ។ ខ្ញុំទ្រាំលបមើលដោយការអន្ទះអន្ទែងចិត្ត ដែលជាការពិបាកសរសេរពណ៌នា អំពីសភាពនៃចិត្តរបស់ខ្ញុំ ក្នុងខណៈនោះបាន ។ មានខណៈចិត្តខ្លះ ខ្ញុំចង់ឈប់ទ្រាំលបមើលព្រោះក្រែងទប់ចិត្តពុំបាន តែចិត្តមួយទៀត បេះតែជម្រុញឲ្យលបមើលតាំងញ័រជើងដៃទៅទៀត ព្រោះការចង់ដឹង ...,

ប្រហែលជាគន្លះម៉ោងក្រោយមក លោកវរសេនីយត្រី ហាង់ឡូ-ជិរើង ក៏បានលាលោកវរសេនីយទោ មាស-ស្អាត ត្រឡប់ទៅគេហដ្ឋានរបស់លោកវិញ ។ លោក មាស-ស្អាត បានជូនមិត្តសំឡាញ់របស់លោក ចុះពីលើផ្ទះ ។ ខណៈនោះខ្ញុំអរព្រោះនឹកថា លែងបានឃើញរឿងល្ខោនជីតាក្រក់សក់ក្រសៅក្នុងរបស់ខ្ញុំទៀតហើយ ។ ពេលនេះខ្ញុំទៅគិតទាក់ទងចិត្តនឹងនាង ជរី ។ ខ្ញុំនឹកឆ្ងល់ថា ហេតុអ្វីក៏នាង ជរី ពុំសំដែងការគួរសមជូនដំណើរភ្ញៀវពិសេសនេះ ដូចភ្ញៀវដទៃផង... ខ្ញុំលបមើលគេទៀត ។

ខ្ញុំកើបចិត្តដោយការឆ្ងល់ជាខ្លាំង ។ នៅពេលដែលលោកវរសេនីយទោ មាស-ស្អាត ជូនដំណើរភ្ញៀវចេញផុតពីកន្លែងនោះបន្តិចទៅ ខ្ញុំបានឃើញនាង ជរី ស្ទុះក្លែកទៅទាក់សោខ្លូដែកដែលផ្អែកទៅនឹងជញ្ជាំងខាងកើត ។ ក្នុងខណៈជាបន្ទាប់នេះ នាងបានដកយកកញ្ចប់ក្រដាសមួយកញ្ចប់



ហើយបិទសោទៅវិញភ្លាម រួចហើយនាងបោះកញ្ចប់នេះ ឲ្យទៅ យ៉ី-យ៉ាំងញី ដែលកំពុងដើរប្រមូលកែវទុកដាក់ ។

ខ្ញុំដណ្ដឹងសួរខ្លួនឯងថា នាង ជរី លួចអ្វី? នឹងថាប្រាក់ក៏ដូចជាពុំសម ព្រោះមើលទៅដូចជាមិនជាច្រើនប៉ុន្មាន លុមឲ្យនាងដាច់ចិត្តលួច? របស់អ្វី? មាសពេជ្រក៏ដូចជាពុំទំងន់ព្រោះកញ្ចប់នោះមានសភាពទទេៗ? ក្រែងមានកិច្ចការអ្វីទេដឹង? ឬមួយនាងជាចារនារីចាំលបលួចការអ្វីពីលោកវរសេនីយទោ មាស-ស្អាត? ខ្ញុំនឹកព្រួចដល់ការម្យ៉ាងដែលខ្ញុំធ្លាប់ដឹង ។ ខ្ញុំសង្ស័យថា កញ្ចប់ក្រដាសនោះប្រហែលជាកញ្ចប់ក្រដាសពិសេសអ្វីម្យ៉ាង ឬកិច្ចការសម្ងាត់ក្នុងកងទ័ព ឬ ក៏ជាអក្សរកូនសោសម្ងាត់សម្រាប់ប្រើប្រាស់ក្នុងកងទ័ពជាពុំខាន ព្រោះលោកវរសេនីយទោ មាស-ស្អាត ត្រូវបានទទួលភារៈជាអ្នកកែងអក្សរកូនសោ ទីងកាន់ការសម្ងាត់ក្នុងកងទ័ព ។ ក្នុងខណៈដែលខ្ញុំគិតដូច្នេះ ខ្ញុំចង់បើកទ្វារចេញ